ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាពជាតិ
# ស្តីពី
# ការអប់រំពហុភាសា

## ២០១៥-២០១៨

តុលា ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា
# ២០១៥ - ២០១៨

តុលា ២០១៥

# អារម្ភកថា

អនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលជាក្របខ័ណ្ឌនៃច្បាប់មួយរបស់សហប្រជាជាតិ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយសាលាកុមារមេត្រី និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា (ដូចជា UNICEF, CARE, Sida និង DFAT ជាដើម) បានរៀបចំផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា (MENAP) នេះឡើង ដើម្បីធានាឱ្យកុមារាកុមារីកម្ពុជាគ្រប់រូប ដែលមកពីសហគមន៍ជនជាតិដើមភាគតិចអាចទទួលបាន និងរៀនចប់ការអប់រំប្រកបដោយគុណភាព និងឆ្លើយតបចំពោះគោលការណ៍នៃការអប់រំសម្រាប់ទាំងអស់គ្នា ដោយអនុវត្តកម្មវិធីអប់រំពហុភាសាជាស្ពាន ដើម្បីកុមារអាចបន្តការសិក្សាទៅកំរិតខ្ពស់ទៀត។ ជាការពិត ការរៀនភាសាអ្វីមួយ ដូចជា ភាសាខ្មែរ ជាដើម ដែលមិនមែនជាភាសាប្រើនៅក្នុងគ្រួសាររបស់កុមារ តែងនាំឱ្យកុមាររៀនខ្សោយ ឈានទៅបោះបង់ការសិក្សា និងបាត់បង់ឱកាសជាច្រើន នៅក្នុងការអប់រំ។ ជាពិសេស ការអប់រំត្រូវផ្តោតលើគោលដៅទី ៤ នៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោយឆ្នាំ ២០១៥ ដែលចែងយ៉ាងច្បាស់ថា "ធានាឱ្យមានការអប់រំបញ្ចូលគ្នា ប្រកបដោយសមធម៌ និងគុណភាព និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជននិងកីឡា នៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកដាក់លើការផ្តល់ការអប់រំពហុភាសា ដែលជាសមាសភាគដ៏សំខាន់មួយនៃគោលនយោបាយជាតិសាលាកុមារមេត្រី ដើម្បីផ្តល់ការអប់រំដល់កុមារជនជាតិដើមភាគតិច ដែលមិនមែនជាអ្នកនិយាយភាសាខ្មែរ (ភាសាជាតិ) ពីកំណើត។

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា មានចក្ខុវិស័យធានាយ៉ាងណាឱ្យកុមារជនជាតិភាគតិចគ្រប់រូប អាចទទួលបានការអប់រំយ៉ាងតិចកម្រិតមូលដ្ឋាន ដោយប្រើប្រាស់ភាសាកំណើតរបស់ពួកគេ នៅមត្តេយ្យ និង នៅដំណាក់កាលបីឆ្នាំដំបូងនៃការសិក្សានៅបឋមសិក្សា។ ការអប់រំពហុភាសា គឺជាយុទ្ធសាស្ត្រ ដែលអនុវត្តនៅថ្នាក់មត្តេយ្យសិក្សា និងបឋមសិក្សា ដើម្បីបង្កលក្ខណៈឱ្យកុមារជនជាតិដើមភាគតិច និងជនជាតិភាគតិច អាចកសាងមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ការរៀនសូត្រ និងសម្រេចឱ្យបាននូវលទ្ធផលនៃការសិក្សា ហើយចុងក្រោយ ផ្តល់លទ្ធភាពឱ្យពួកគេអាចក្លាយជាប្រជាពលរដ្ឋ ដែលមានតម្លៃ និងមានប្រយោជន៍ សម្រាប់ប្រទេសកម្ពុជា។ ការស្រាវជ្រាវបង្ហាញថា ជាទូទៅ កុមាររៀនសូត្របានល្អបំផុត នៅពេលគេប្រើភាសា ដែលគេនិយាយនៅក្នុង គ្រួសារ។ ការយល់ដឹងរបស់កុមារ មានការរីកចម្រើន តាមរយៈការភ្ជាប់ទំនាក់ទំនងគំនិតថ្មីៗ ជាមួយនឹងគោលគំនិតឬបញ្ញត្តិដែលពួកគេស្គាល់។ ប្រសិនបើ ដំណើរការបង្រៀន ទស្សនទាន និងភាសា មានលក្ខណៈផ្សេងពី បរិបទរស់នៅរបស់ពួកគេ ហើយខ្វះទំនាក់ទំនងជាមួយនឹងជីវិតប្រចាំថ្ងៃរបស់កុមារ នោះការរៀនសូត្រនឹងកាន់តែលំបាកទៅៗជាមិនខាន។ ដូច្នេះ ការអប់រំពហុភាសា គឺជាស្ពានដ៏មានសារៈសំខាន់ សម្រាប់ភ្ជាប់កុមារកម្ពុជា ដែលមិននិយាយភាសាខ្មែរនៅផ្ទះ ទៅនឹងការអប់រំក្នុងប្រព័ន្ធ។

ផែនការសកម្មភាពជាតិស្ដីពីការអប់រំពហុភាសានេះអាចជាមគ្គុទ្ទេសក៍តម្រង់ទិស ក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសានៅតាមបណ្ដាខេត្តនៅភាគឦសាន និងដោយមាន ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍនានា ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្ដល់ការគាំទ្រដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រាជធានី ដើម្បីពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីអប់រំពហុភាសានេះ នៅក្នុងខេត្តទាំងប្រាំ ពោលគឺខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងព្រះវិហារ ដែលមានប្រជាជនជនជាតិដើមភាគតិចជាច្រើននាក់រស់នៅទីនោះ។ ផែនការនេះព្យាករណ៍ថានឹងបង្កើនការផ្ដល់សាលាអប់រំពហុភាសាឱ្យបានគ្រប់គ្រាន់តាមតម្រូវការ ក៏ដូចជាផ្ដល់ការគាំទ្រជាផ្លូវការ ដល់ការអនុវត្តកម្មវិធីអប់រំពហុភាសាឲ្យទទួលបានជោគជ័យផងដែរ។

តាងនាមឱ្យក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសង្ឃឹមថា ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន សហគមន៍ និងមាតាបិតា មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំស្រុក និងសាលារៀន ដែលពាក់ព័ន្ធ នឹងប្រើប្រាស់ផែនការសកម្មភាពជាតិស្ដីពីការអប់រំពហុភាសានេះ ជាមគ្គុទ្ទេសក៍តម្រង់ទិសសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ខេត្តនិងស្រុក ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍សាលារៀនរបស់ខ្លួន ដើម្បីផ្ដល់លទ្ធភាពឱ្យកុមារអាចទទួលបានការអប់រំប្រកបដោយគុណភាពនិងសមធម៌ ធានាបាននូវការអប់រំមួយដ៏មានប្រសិទ្ធភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ឯកឧត្ដម បណ្ឌិត ហង់ ជួនណារ៉ុន**

# មាតិកា


**អារម្ភកថា** ........ 1

**មាតិកា** ........ 3

**បញ្ជីអក្សរកាត់** ........ 5

**១. ច្បាប់ជាតិ និងអន្តរជាតិ** ........ 6

១.១. រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ........ 6

១.២. អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ........ 6

១.៣. ច្បាប់ស្តីពីការអប់រំ ........ 7

**២. ក្រុមជនជាតិដើមភាគតិចនៅខេត្តភាគឦសាន** ........ 8

**៣. សាវតារ** ........ 9

**៤. ចក្ខុវិស័យ** ........ 10

**៥. គោលបំណង** ........ 10

**៦. បរិបទប្រទេស** ........ 11

**៧. បរិបទនៃការអប់រំ នៅតាមខេត្តតំបន់ខ្ពង់រាប** ........ 11

**៨. ការធ្វើឱ្យកម្មវិធីអប់រំពហុភាសាមាននិរន្តរភាព** ........ 14

**៩. យុទ្ធសាស្ត្រ** ........ 15

៩.១. ការកសាងសមត្ថភាព ជាពិសេស ដល់គ្រូ និងការបណ្តុះបណ្តាលគ្រូ ........ 15

៩.២. ផ្តល់សម្ភារបង្រៀន និងរៀន ........ 16

៩.៣. ការសម្របសម្រួល ទិន្នន័យនិងព័ត៌មាន ការពិនិត្យតាមដាន និងការវាយតម្លៃ ........ 16

៩.៤. ការពង្រីកការផ្តល់ការអប់រំពហុភាសា ........ 17

៩.៥. ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន ........ 19

៩.៦. សាលារៀនសហគមន៍ ........ 19

**១០. បញ្ហាទូទៅដែលត្រូវដោះស្រាយ** ........ 19

**១១. គុណភាព ការពិនិត្យតាមដាន និងការវាយតម្លៃ** ........ 20

**១២. ស្ថិតិជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា** ........ 21
១២.១. វិសាលភាពនៃការអប់រំពហុភាសា បែងចែកតាមខេត្ត ........ 21
១២.២. កុមារជនជាតិដើមភាគតិច និងស្ថានភាពនៃការអប់រំរបស់ពួកគេ ........ 23
១២.៣. កុមារជនជាតិដើមភាគតិច និងស្ថានភាពនៃការអប់រំរបស់ពួកគេ នៅកម្រិតមត្តេយ្យសិក្សា ........ 24
១២.៤. កុមារជនជាតិដើមភាគតិច និងស្ថានភាពនៃការអប់រំរបស់ពួកគេ នៅកម្រិតបឋមសិក្សា ........ 25
១២.៥. ទិដ្ឋភាពទូទៅនៃការផ្តល់មូលនិធិសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ........ 26
**ឧបសម្ព័ន្ធ** ........ 29
ឧបសម្ព័ន្ធទី ១ ៖ ប្រវត្តិសង្ខេបនៃការអប់រំពហុភាសានៅក្នុងប្រទេសកម្ពុជា ........ 29
ឧបសម្ព័ន្ធទី ២ ៖ ក្របខ័ណ្ឌពេលវេលានៃព្រឹត្តិការណ៍សំខាន់ៗ ពាក់ព័ន្ធនឹងការអប់រំពហុភាសា នៅក្នុងប្រទេសកម្ពុជា ........ 31
ឧបសម្ព័ន្ធទី ៣ ៖ តួនាទីរបស់អង្គការ និងស្ថាប័ននានា នៅក្នុងការអភិវឌ្ឍការអប់រំពហុភាសា នៅ ក្នុងប្រទេសកម្ពុជា ........ 32
ឧបសម្ព័ន្ធទី ៤ ៖ គំរូអប់រំពហុភាសាដែលអនុវត្តនៅក្នុងការអប់រំក្នុងប្រព័ន្ធនៅកម្ពុជា ........ 35
ឧបសម្ព័ន្ធទី ៥ ៖ សន្ទរកថាស្តីពីការអប់រំពហុភាសារបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ........ 36
ឧបសម្ព័ន្ធទី ៦ ៖ ភាពស្ទាត់ជំនាញខាងភាសាចំនួន ២ ប្រភេទ ........ 40
ឧបសម្ព័ន្ធទី ៧ ៖ សទ្ទានុក្រមនៃវាក្យសព្ទ ដែលច្រើនប្រើនៅក្នុងការអប់រំពហុភាសា ........ 43

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| AOP | Annual Operation Plan | ផែនការប្រតិបត្តិប្រចាំឆ្នាំ |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AusAID | Australian Agency for International Development | ទីភ្នាក់ងារអូស្ត្រាលី ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ |
| CARE | | អង្គការថែរ |
| CDD | Curriculum Development Department | នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា |
| CFS | Child Friendly School | សាលាកុមារមេត្រី |
| CPS | Community Preschool | សាលាមត្តេយ្យសហគមន៍ |
| DTMT | District Training and Monitoring Team | ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ |
| DFAT | Department of Foreing Affairs and Trade (Australia) | ក្រសួងកិច្ចការបរទេសនិងពាណិជ្ជកម្ម(អូស្ត្រាលី) |
| ECED | Early Childhood Education Department | នាយកដ្ឋានអប់រំកុមារតូច |
| EMC | Ethnic Minority Children | កុមារជនជាតិដើមភាគតិច |
| EMIS | Education Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| HCEP | Highland Children's Education Project | គម្រោងអប់រំកុមារតំបន់ខ្ពង់រាប |
| ICC | International Co-operation Cambodia | អង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជា |
| MENAP | Multilingual Education National Action Plan | ផែនការសកម្មភាពជាតិស្តីពីការអប់រំ ពហុភាសា |
| MLE | Multilingual Education | ការអប់រំពហុភាសា |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| NGO | Non-Governmental Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| PED | Primary Education Department | នាយកដ្ឋានបឋមសិក្សា |
| POE | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត |
| PRD | Pedagogical Research Department | នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ |
| PTTC | Provincial Teacher Training College | សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត |
| NTFP | Non Timber Forest Products | អនុផលព្រៃឈើ |
| UNICEF | United Nations Children's Fund | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# ១. ច្បាប់ជាតិ និងអន្តរជាតិ

## ១.១. រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចតាមច្បាប់ ក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋគ្រប់រូបរបស់ខ្លួន ស្របតាមសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ជាតិនានា។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ[1]។

រដ្ឋធម្មនុញ្ញក៏ចែងពីការធានា និងការប្តេជ្ញាចិត្តច្បាស់លាស់ ពាក់ព័ន្ធនឹងការផ្តល់ការការពារនិងការអប់រំដល់កុមារផងដែរ។ រដ្ឋធម្មនុញ្ញចែងថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងនៅ ក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ"[2]។

ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តនេះ មាត្រា ៦៦ ទំព័រ ២២ ចែងយ៉ាងច្បាស់ថា រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។

## ១.២. អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)

អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាក្របខ័ណ្ឌច្បាប់របស់សហប្រជាជាតិ ដែលធានាឱ្យមានការលើកកម្ពស់ និងគោរពរាល់សិទ្ធិទាំងអស់របស់កុមារ ពីសំណាក់រដ្ឋជាសមាជិក។

មាត្រា ២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចែងថា រដ្ឋភាគីត្រូវគោរពនិងធានាសិទ្ធិដូចចែងនៅក្នុងអនុសញ្ញានេះ ដល់កុមារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ របស់ម្តាយឪពុកកុមារ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ។

---

[1]មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ២០១០

[2]កថាខណ្ឌ ១ និង ២ មាត្រា ៤៨ ទំព័រ ១៦

មាត្រា ២០ កថាខណ្ឌ ៣ ក៏ចែងពីការធានានូវចម្រុះភាពនៃជាតិពន្ធុ សាសនា វប្បធម៌ និង ភាសារបស់កុមារផងដែរ។ មាត្រានេះចែងថា ការថែទាំនេះ រាប់បញ្ចូលជាអាទិ៍ ការដាក់កុមារឱ្យគេទទួលចិញ្ចឹម កាហ្វាឡានៃច្បាប់អ៊ីស្លាម ការសុំកូន ឬបើសិនជាចាំបាច់ ការដាក់កុមារនៅក្នុងស្ថាប័នសមស្របដើម្បីថែទាំកុមារ។ នៅពេលពិចារណារកដំណោះស្រាយ ត្រូវយកចិត្តទុកដាក់ ការចាំបាច់ឱ្យមានការអប់រំកុមារ និងលើការអប់រំខាងជាតិពន្ធុ សាសនា វប្បធម៌ និងភាសារបស់កុមារ។

រដ្ឋភាគីយល់ស្របថា ការអប់រំកុមារត្រូវតែឆ្ពោះទៅរកទិដ្ឋភាពជាច្រើនក្នុងសង្គម ដូចជា ការអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ និងបរិស្ថាន ។ល។ ជាដើម។ មាត្រា២៩ ចំណុច១ វាក្យខណ្ឌ(ឃ) ចែងថា ការបណ្តុះបណ្តាលកុមារសម្រាប់ការរស់នៅប្រកបដោយការទទួលខុសត្រូវ ក្នុងសង្គមសេរី ក្នុងស្មារតីយោគយល់គ្នា សន្តិភាព អត់ឱនឱ្យគ្នា ស្មើភាពគ្នារវាងភេទ និងមិត្តភាពរវាងប្រជាជាតិទាំងអស់ ក្រុមជាតិពន្ធុ ជនជាតិ និងសាសនា និងជនអន្តោប្រវេសន៍ ... 

មាត្រា ៣០ ចែងថា "នៅក្នុងរដ្ឋដែលមានជនភាគតិចខាងជាតិពន្ធុ ឬសាសនា ឬភាសា ឬជនអន្តោគ្រាម កុមារជាសមាជិកនៃជនភាគតិច ឬជនអន្តោគ្រាមនេះ មិនត្រូវទទួលរងនូវការដកហូតសិទ្ធិមានជីវភាពវប្បធម៌ សិទ្ធិបង្រៀន ឬប្រតិបត្តិសាសនា ឬប្រើភាសាផ្ទាល់ខ្លួន ដោយរួមជាមួយសមាជិកផ្សេងទៀតនៃក្រុមរបស់ខ្លួនឡើយ"។

## ១.៣. ច្បាប់ស្តីពីការអប់រំ

ច្បាប់ស្តីពីការអប់រំរបស់ប្រទេសកម្ពុជា កំណត់ពីទិសដៅយ៉ាងច្បាស់លាស់ សម្រាប់ឱ្យក្រសួងទទួលបន្ទុកវិស័យអប់រំរៀបចំនូវយុទ្ធសាស្ត្រ និងកម្មវិធី ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់កុមារទាំងអស់ នៅក្នុងប្រទេសកម្ពុជា ដោយមិនគិតពីសាវតារសេដ្ឋកិច្ច ការប្រតិបត្តិខាងវប្បធម៌ និងប្រពៃណី និងជាតិពន្ធុ ... ឡើយ។ បើទោះបីជាភាសាខ្មែរ គឺជាភាសាជាតិយ៉ាងណាក៏ដោយ ច្បាប់នេះ អនុញ្ញាតឱ្យមានភាពបត់បែន នៅក្នុងការផ្តល់ការអប់រំដល់កុមារមកពីសហគមន៍ជនជាតិភាគតិច ដូចដែលមានចែងនៅក្នុងមាត្រា ២៤ ស្តីពីភាសាប្រើប្រាស់ ក្នុងការបង្រៀន និងរៀនថា "ភាសាខ្មែរជាភាសាយាន និងជាមុខវិជ្ជាមួយនៃកម្មវិធីសិក្សាគោល នៅសាលារៀនចំណេះទូទៅសាធារណៈ។ ចំពោះសាលារៀនចំណេះទូទៅឯកជន ត្រូវមានកម្មវិធីអប់រំភាសាខ្មែរ ជាមុខវិជ្ជាជាគោលមួយនៃកម្មវិធីសិក្សារបស់ខ្លួន។ ភាសាសម្រាប់ប្រើប្រាស់ចំពោះអ្នកសិក្សាសញ្ជាតិខ្មែរ ដែលមានកំណើតជាខ្មែរជនជាតិភាគតិច ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ។ ភាសាបរទេសដែលជាភាសាអន្តរជាតិ ត្រូវកំណត់ដាក់លាក់ជាមុខវិជ្ជាសិក្សាមួយសម្រាប់កម្មវិធីសិក្សាគោលនៃការអប់រំចំណេះទូទៅ ស្របតាមសេចក្តីត្រូវការរបស់អ្នកសិក្សា"។

ផែនការសកម្មភាពនេះ ក៏យោងទៅតាម អនុសញ្ញាអន្តរជាតិ សេចក្តីប្រកាសអន្តរជាតិ គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និងសេចក្តីប្រកាស ដូចខាងក្រោម ៖

- អនុសញ្ញាអង្គសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច
- សេចក្តីប្រកាសស្តីពីការអប់រំ ដាកា ឆ្នាំ ២០០០

- គោលនយោបាយជាតិស្ដីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ ២០០៩
- ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា
- គោលនយោបាយជាតិស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១០
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ ២០១៤-២០១៨
- ប្រកាសលេខ ៤៨ ឆ្នាំ ២០១៣ ស្ដីពីការកំណត់ភាសាសម្រាប់អ្នកសិក្សាសញ្ជាតិខ្មែរដែលមានដើមកំណើតជាខ្មែរជនជាតិភាគតិច។

## ២. ក្រុមជនជាតិដើមភាគតិចនៅខេត្តភាគឦសាន

បើតាមទិន្នន័យ ដែលផ្ដល់ដោយនាយកដ្ឋានស្ថិតិ និងសេវាព័ត៌មាន[3] នៃក្រសួងផែនការ ចំនួនជនជាតិដើមភាគតិច ដែលរស់នៅខេត្តភាគឦសាននៃប្រទេសកម្ពុជារួមមានដូចខាងក្រោម ៖

ខេត្តរតនគិរី ៖ ខេត្តរតនគិរី មានចំនួនប្រជាជនសរុប ១៨៣៦៩៩ នាក់ ដែលក្នុងនោះមាន ១១៧១២៩នាក់ ស្ថិតនៅក្នុងក្រុមជនជាតិដើមភាគតិច។ ដូច្នេះជនជាតិដើមភាគតិចមាន ៦៤% នៃប្រជាជន សរុបក្នុងខេត្តនេះ។ ក្រុមជនជាតិដែលមានចំនួនច្រើនជាងគេនៅក្នុងខេត្តនេះ គឺជនជាតិទំពួន ដែលមានចំនួនសរុប ៥១០៥៣នាក់។

ខេត្តមណ្ឌលគិរី ៖ ខេត្តមណ្ឌលគិរីមានចំនួនប្រជាជនសរុប ៧២៦៨០នាក់ ដែលក្នុងនោះមាន ៤១៩៦៥នាក់ស្ថិតនៅក្នុងក្រុមជនជាតិដើមភាគតិច។ ជនជាតិព្នង គឺ ជាក្រុមជនជាតិដើមភាគតិចដែលមានចំនួនច្រើនជាងគេនៅក្នុងខេត្តនេះ ដែលមានចំនួន ៣៧២៥៨នាក់។ ជនជាតិដើមភាគតិចមាន ៥៨% នៃចំនួនប្រជាជនសរុបក្នុងខេត្តនេះ។

ខេត្តស្ទឹងត្រែង ៖ ខេត្តស្ទឹងត្រែងមានចំនួនប្រជាជនសរុប ១២២៧៩០នាក់។ ខេត្តនេះមានប្រជាជននិយាយភាសាផ្សេងខុសពីភាសាខ្មែរ ១៧៣០១នាក់ (១៤%) ដែលក្នុងនោះមានជនជាតិឡាវ និងជនជាតិចាម។ ជនជាតិកាវ៉ែតសរុបមានចំនួន ៤៩១២នាក់ គឺជាក្រុមជនជាតិដើមភាគតិចដែលមានចំនួនច្រើនជាងគេ។

ខេត្តព្រះវិហារ ៖ ខេត្តព្រះវិហារមានប្រជាជនសរុប ២៣៥៣៧០នាក់។ ខេត្តនេះមានអ្នកនិយាយភាសាផ្សេងទៀតក្រៅពីភាសាខ្មែរ ៦៨៥៣នាក់ (៣%)។ ជនជាតិដើមភាគតិច ចំនួន ៦១៣៦នាក់ ជាជនជាតិកួយ។

ខេត្តក្រចេះ ៖ ខេត្តក្រចេះមានប្រជាជនសរុប ៣៤៤១៩៥នាក់។ ខេត្តនេះមានអ្នកនិយាយភាសាផ្សេងទៀតក្រៅពីភាសាខ្មែរ ចំនួន ២២០៣៥នាក់ (៦%) ដោយជនជាតិព្នងគឺជាក្រុមធំជាងគេ ដែលមានប្រជាជន ៨៥៩២នាក់។

[3] EMIS ពុំបានធ្វើការកត់ត្រាពីជាតិពន្ធុរបស់សិស្សឡើយ។ នេះគឺជាអនុសាសន៍មួយ នៅក្នុងឯកសារនេះ។ ជាតិពន្ធុក៏មិនត្រូវបានកត់ត្រានៅក្នុងជំរឿនដែរ នាយកដ្ឋានស្ថិតិនៃក្រសួងផែនការកត់ត្រាភាសាកំណើតរបស់ពលរដ្ឋខ្មែរ។ តួលេខដែលត្រូវបានកត់ត្រា គឺផ្អែកទៅតាមភាសាកំណើតដែលអ្នកនិយាយប្រាប់ដោយខ្លួនឯង។ នៅក្នុងខេត្តព្រះវិហារ និងស្ទឹងត្រែង អាចមានករណីដែលជនជាតិកួយ និងឡាវជាច្រើននាក់ចេះនិយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ ដូច្នេះបានចាត់ទុកភាសាខ្មែរថាជាភាសាកំណើតរបស់ខ្លួន។

ក្រុមជនជាតិដើមភាគតិចពីរផ្សេងទៀត មានចំនួនច្រើនដែរ គឺជនជាតិចាមចំនួន៧៧១៧នាក់ និងជនជាតិក្រោលចំនួន ៤៥៤៩នាក់។

## ៣. សាវតារ

ភាសាដែលគេប្រើក្នុងសាលារៀន ច្រើនតែជាភាសាផ្លូវការឬភាសាជាតិ ដែលប៉ះពាល់ជាអវិជ្ជមាន ដែលមាន ផលប៉ះពាល់អវិជ្ជមានខ្លាំងមកលើការអប់រំរបស់កុមារជនជាតិដើមភាគតិច ដែលមិននិយាយភាសាជាតិ។ ក្នុងប្រទេស ជាច្រើនលើពិភពលោក កុមារជាច្រើននាក់ចាប់ផ្តើមចូលរៀននៅសាលារៀនដែលគ្រូរបស់ពួកគេនិយាយមកកាន់ពួកគេ ជាភាសាមួយដែលពួកគេមិនយល់។ នៅកន្លែងផ្សេងទៀតគ្រូចាប់ផ្តើមប្រាស្រ័យទាក់ទងជាមួយកុមារ ដោយប្រើប្រាស់ ភាសារបស់កុមារ ប៉ុន្តែនៅពេលដែលចាប់ផ្តើមបង្រៀនអក្សរ និងលេខ គ្រូប្រើប្រាស់ភាសាដែលកុមារមិនយល់។

នៅពេលដែលកុមារមិនយល់ភាសាដែលគ្រូកំពុងប្រើប្រាស់ ជារឿយៗ ពួកគេរៀនចម្លង និងទន្ទេញអក្សរ និង លេខ ប៉ុន្តែមិនយល់អ្វីទាំងអស់ ហើយមិនអាចយកអក្សរ និងលេខទាំងនោះមកប្រើឱ្យមានប្រយោជន៍ឡើយ។ ការរៀន បែបនេះត្រូវបានគេហៅថា “ការរៀនទន្ទេញរត់មាត់ (Barking at Print)”។ នៅក្នុងស្ថានភាពបែបនេះ មានកុមារជាច្រើន នាក់ដែលបោះបង់ការសិក្សាព្រមគ្នា ឯកុមារផ្សេងទៀតប្រឡងធ្លាក់ និងរៀនត្រួតថ្នាក់ជាច្រើនឆ្នាំ។

មនុស្សពេញវ័យជារឿយៗ មានមូលហេតុដ៏មានឥទ្ធិពលក្នុងការជ្រើសរើសភាសាបង្រៀននិងរៀនដែលកុមារ មិនចេះ។ ប៉ុន្តែមានការបង្ហាញថា ប្រសិនបើភាសាបង្រៀននិងរៀននៅសាលាខុសពីភាសាដែលកុមារប្រើនៅផ្ទះជាមួយ គ្រួសារ និងមិត្តភក្តិ វាគឺជាមូលហេតុធំមួយ ដែលនាំឱ្យកុមារជាច្រើននាក់ត្រូវបរាជ័យនៅក្នុងការអប់រំ។ នៅក្នុងស្ថាន ភាពនេះ ភាសាគឺជាឧបសគ្គចម្បងចំពោះការអប់រំ។ នៅបណ្តាប្រទេសជាច្រើន ការប្រើប្រាស់ភាសាមិនសមស្របក្នុង សាលារៀន គឺជាការដើរផ្ទុយពីកិច្ចខិតខំដើម្បីពង្រឹងគុណភាពអប់រំ និងនាំឱ្យខាតបង់នូវធនធាន។

មន្ត្រីរដ្ឋាភិបាល និងអ្នកធ្វើការងារអប់រំជាច្រើន មានការព្រួយបារម្ភអំពីបញ្ហាភាសាដែលប្រើប្រាស់នៅតាម សាលារៀន ប៉ុន្តែមិនប្រាកដថាត្រូវធ្វើបែបណានោះទេ ជាពិសេស នៅពេលដែលមន្ត្រី និងអ្នកធ្វើការងារអប់រំទាំងនេះ ពុំមានលទ្ធភាព ដើម្បីធ្វើការផ្លាស់ប្តូររបៀបចាត់ចែងការងារក្នុងសាលារៀនរបស់ពួកគេទាំងស្រុងបាន។

ឥឡូវនេះ ការអប់រំពហុភាសា ត្រូវបានរដ្ឋាភិបាល និងក្រសួងអប់រំ ក្នុងប្រទេសជាច្រើននៅលើពិភពលោក ចាត់ ទុកថាជាយុទ្ធសាស្រ្តដ៏សំខាន់មួយ នៅក្នុងការជម្នះឧបសគ្គភាសានៅក្នុងការអប់រំ ដែលជួបប្រទះដោយអ្នកនិយាយ ភាសាជនជាតិដើមភាគតិច និងអ្នកនិយាយភាសាដែលមិនមែនជាភាសាប្រើទូទៅនៅក្នុងប្រទេស។

ក្រៅពីឧបសគ្គភាសា នៅមានឧបសគ្គជាច្រើនទៀតចំពោះការផ្តល់សេវាអប់រំដល់សហគមន៍ជនជាតិដើមភាគ តិច។ សហគមន៍ជនជាតិដើមភាគតិចមួយចំនួនធំ រស់នៅក្នុងតំបន់ដាច់ស្រយាល ក្នុងកម្រិតដង់ស៊ីតេទាប និង មាន ឱកាសតិចតួចក្នុងការធ្វើទំនាក់ទំនងជាមួយសង្គមខ្មែរទូទៅ។ ប្រការនេះបានបន្ថែមភាពលំបាកដល់ការ ផ្តល់ការអប់រំ និង ការពិនិត្យតាមដានដើម្បីធានានូវគុណភាព។ កង្វះហេដ្ឋារចនាសម្ព័ន្ធ និងភាពក្រីក្រ នៅក្នុងសហគមន៍ គឺជាផល វិបាក ដែលជារឿយៗ ម្តាយឪពុកយល់ឃើញថា ការអប់រំមិនមានសារៈសំខាន់សម្រាប់កូនរបស់ពួកគេ។

ម៉្យាងទៀត នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ជាពិសេសមនុស្សពេញវ័យ ការអប់រំរបស់ពួកគេនៅមានកម្រិត ក្នុងនោះ ពួកគេភាគច្រើនបានសិក្សាក្នុងប្រព័ន្ធអប់រំតិចតួចបំផុត។

## ៤. ចក្ខុវិស័យ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា គឺថា កុមារកម្ពុជាគ្រប់រូប រួមទាំងកុមារជនជាតិដើមភាគតិចផង មានសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព។

កុមារជនជាតិដើមភាគតិចគ្រប់រូប មានសិទ្ធិទទួលបានការអប់រំកម្រិតមូលដ្ឋាន រួមនឹងការប្រើប្រាស់ភាសាកំណើតរបស់ពួកគេ នៅក្នុងដំណាក់កាលដំបូងៗនៃការអប់រំ។

ការអប់រំពហុភាសា (MLE) គឺជាយុទ្ធសាស្ត្រ ដែលត្រូវបានអនុវត្ត នៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា (ថ្នាក់ទី១ដល់ទី៣) ដើម្បីកសាងនូវមូលដ្ឋានសម្រាប់ឱ្យកុមារជនជាតិដើមភាគតិចអាចបន្តការសិក្សារបស់ពួកគេនៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាបាន ដោយប្រើប្រាស់ភាសាជាតិ ដើម្បីក្លាយខ្លួនជាប្រជាពលរដ្ឋ ដែលមានតម្លៃ និងមានប្រយោជន៍ ចំពោះប្រទេសកម្ពុជា។

តាមរយៈការបំប៉នសមត្ថភាពដល់មន្ត្រីរាជការ ឱ្យបានគ្រប់គ្រាន់ផ្នែកអប់រំពហុភាសា ក្រសួងអប់រំ យុវជន និងកីឡា ធានាឱ្យបាននូវធនធានគ្រប់គ្រាន់ ទាំងផ្នែកធនធានហិរញ្ញវត្ថុទាំងផ្នែកធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យការអប់រំពហុភាសា នៅជាប់យ៉ាងមាំនៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចជា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលនឹងនាំឱ្យការអប់រំពហុភាសាបន្តមាននិរន្តរភាពទៅមុខទៀត។

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា (MENAP) នេះ មានគោលដៅបង្កើនគុណភាពនៃការអប់រំ និងការពង្រីកការអប់រំពហុភាសាគ្រប់រូបភាព។

## ៥. គោលបំណង

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា មានគោលបំណង ៖

១. ដើម្បីធានាយ៉ាងណាឱ្យកុមារាកុមារីជនជាតិដើមភាគតិច អាចទទួលបានការអប់រំប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងការអប់រំសម្រាប់ទាំងអស់គ្នា

២. ដើម្បីកសាងសមត្ថភាពរបស់មន្ត្រីអប់រំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្តការអប់រំពហុភាសា

៣. ដើម្បីពង្រីកការផ្តល់ការអប់រំពហុភាសា នៅតាមខេត្តពាក់ព័ន្ធ និង

៤. ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំពហុភាសា តាមរយៈគណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតា និងអាជ្ញាធរមូលដ្ឋាន។

## ៦. បរិបទវប្បធម៌

នៅក្នុងខេត្តតំបន់ខ្ពង់រាបទាំង ៥ នៅភាគឦសាននៃប្រទេសកម្ពុជា គេប៉ាន់ស្មានថា មានជនជាតិ ដើមភាគតិច ចំនួន ១៨៣២៨២ នាក់ មកពីជាង ១០ ក្រុមជនជាតិ ដែលគេតែងហៅក្រុមនេះជារួមថា "ជនជាតិដើមភាគតិច"។ ពួកគេភាគច្រើន រស់នៅតាមភូមិដាច់ស្រយាលដែលមានការលំបាក ឬពុំអាចទទួលបានសេវាសុខភាព ឬសេវាអប់រំទាល់តែសោះ និងមានលទ្ធភាពតិចតួចបំផុតក្នុងការធ្វើសកម្មភាព ពាណិជ្ជកម្ម។

វប្បធម៌ និងភាសារបស់ក្រុមជនជាតិដើមភាគតិច មានលក្ខណៈខុសពីវប្បធម៌ និងភាសារបស់ជនជាតិខ្មែរទូទៅ។ គ្រប់ក្រុមជនជាតិដែលរស់នៅក្នុងតំបន់នេះ និយាយភាសាផ្ទាល់ខ្លួនរបស់ពួកគេ និងគោរពប្រតិបត្តិសាសនារៀងៗខ្លួន។ ក្នុងចំណោមពួកគេ មានតែមួយចំនួនតូចប៉ុណ្ណោះ ដែលចេះនិយាយ ឬយល់ភាសាខ្មែរដែលជាភាសាជាតិផ្លូវការរបស់ប្រទេសកម្ពុជា ហើយសមត្ថភាពរបស់ពួកគេនៅមានកម្រិត។ ប្រព័ន្ធអក្ខរក្រមនៃភាសាជនជាតិដើមភាគតិចចំនួនប្រាំ[4] ក្នុងចំណោមភាសាទាំងអស់ប្រមាណ២៤ភាសា ជាភាសាដែលមានគេនិយាយទូលំទូលាយច្រើន ហើយដែលយកអក្ខរក្រមខ្មែរធ្វើជាគោល បានទទួលការអនុម័តនៅក្នុងឆ្នាំ ២០០៣។ ដើម្បីសម្រួលដល់ការសិក្សារៀនសូត្ររបស់សិស្ស និងការបង្រៀនរបស់គ្រូដែលមិនចេះភាសាជនជាតិដើមភាគតិច យើងត្រូវរៀបចំសម្រួលឱ្យមានឯកសារតាម របៀបត្រាប់សូរ ដោយយកអក្ខរក្រមខ្មែរធ្វើជាគោលសម្រាប់សិស្សថ្នាក់ទី១ ទី២ និងទី៣ តាមស្មារតីប្រកាសលេខ៤៨ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា។

សកម្មភាពសេដ្ឋកិច្ចចម្បងៗរបស់ជនជាតិដើមភាគតិច ផ្តោតលើការបង្កបង្កើនផលស្រូវ និងកសិកម្មពនេចរ ប៉ុន្តែដំណាំពាណិជ្ជកម្មដូចជា ស្វាយចន្ទី កាហ្វេ និងសណ្តែកសៀង ជាដើម កាន់តែមានសារៈសំខាន់ខ្លាំងឡើង។ ផ្ទុយទៅវិញ ជនជាតិខ្មែរដែលរស់នៅក្នុងសង្គម "ទូទៅ" នៅតាមទីប្រជុំជន ឬផ្លូវធំៗ ពួកគេភាគច្រើនជាអ្នកប្រកបរបរអាជីវកម្ម ពាណិជ្ជកម្ម និងធ្វើការងារក្នុងជួររដ្ឋាភិបាល។

## ៧. បរិបទនៃការអប់រំ នៅតាមខេត្តតំបន់ខ្ពង់រាប

សូចនាករអប់រំនៅតាមបណ្តាខេត្តខ្ពង់រាបនៅភាគឦសាននៃប្រទេសកម្ពុជា មានកម្រិតទាប បើធៀបនឹងខេត្តនៅតំបន់វាលទំនាប ហើយស្ថានភាពនេះគឺមានលក្ខណៈអន់ខ្សោយបំផុត សម្រាប់សហគមន៍ជនជាតិដើមភាគតិច។

ការចូលរួមរបស់កុមាររស់នៅតាមតំបន់ខ្ពង់រាប ជាពិសេស កុមារដែលរៀនចាប់ពីថ្នាក់ទី ៤ ឡើងទៅ មានគម្លាតដ៏ធំដោយសារតែមានកុមារតិចតួចប៉ុណ្ណោះ ដែលអាចបន្តទៅរៀននៅកម្រិតមធ្យមសិក្សា។ នៅក្នុងសហគមន៍ភាគច្រើនពុំទាន់មានសាលារៀនគ្រប់គ្រាន់នៅឡើយ បើទោះជាមានសាលារៀនក៏ដោយ ក៏សាលារៀននោះពុំមានដំណើរការល្អដែរ ដោយសារតែមានគ្រូតិចតួចប៉ុណ្ណោះមកពីក្រសួងអប់រំ យុវជន និងកីឡា ដែលមកបង្រៀននៅកន្លែងទាំងនោះ

[4] រួមមានភាសាគ្រឹង ទំពួន កាវ៉ែត ព្រៅ និងព្នង

តែជាទូទៅ គ្រូទាំងនោះមានអវត្តមានញឹកញាប់ថែមទៀត។ ឧបសគ្គនៃភាពជោគជ័យក្នុងការចូលរួមមួយទៀត គឺការបង្រៀននិងរៀននៅតាមសាលារដ្ឋដោយប្រើភាសាខ្មែរ មនុស្សពេញវ័យជនជាតិដើមភាគតិចជាច្រើននាក់មិនយល់ភាសាខ្មែរ។ ហេតុនេះ យើងសង្កេតឃើញថាកុមារជនជាតិដើមភាគតិចកាន់តែច្រើននាក់ថែមទៀតដែលមិនយល់ភាសាខ្មែរ។ ដូច្នេះ អត្រាសិក្សា និងអត្រាគង់វង្សរបស់កុមារជនជាតិដើមភាគតិច នៅតាមបណ្តាខេត្តទាំងនេះ មានកម្រិតទាបជាងគេនៅក្នុងប្រទេសកម្ពុជា។

ការអង្កេតជាច្រើន បានធ្វើឡើងដោយអង្គការឃែរ (CARE) និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត នៅក្នុងខេត្តទាំងនេះ បង្ហាញថា សមាជិកភាគច្រើនរបស់សហគមន៍ជនជាតិដើមភាគតិច ឯកភាពថា ការអប់រំមានសារៈសំខាន់សម្រាប់កូនៗរបស់ពួកគេ។ ឪពុកម្តាយជនជាតិភាគតិចច្រើនលើសលុបផ្តល់តម្លៃខ្ពស់ដល់ការអប់រំ ប្រសិនបើការអប់រំត្រូវបានសម្របសម្រួលឱ្យស្របតាមវប្បធម៌របស់ពួកគេ និងបានផ្តល់ឱកាសដល់កូនៗរបស់ពួកគេ ដើម្បីបន្តប្រើប្រាស់ភាសារបស់សហគមន៍ ហើយក្នុងពេលជាមួយគ្នា ពួកគេក៏មានឱកាសរៀនភាសាខ្មែរផងដែរនោះ។

តាមរយៈមេរៀន ដែលទទួលបានពីជោគជ័យ នៅក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសានៅសាលាបឋមសិក្សានៅក្នុងឆ្នាំ ២០១១ កម្មវិធីនេះក៏បានដាក់ឱ្យអនុវត្តនៅក្នុងកម្រិតមត្តេយ្យសិក្សាផងដែរ។ ឯកសារបណ្តុះបណ្តាលស្តីពីការអប់រំពហុភាសានៅមត្តេយ្យសិក្សា ត្រូវបានរៀបចំឡើង ដោយសហការជាមួយអង្គការ CARE សម្រាប់ភាសាជនជាតិដើមភាគតិចចំនួន៥ ក្នុងខេត្ត៥នៃភាគឦសាន។ សាលាមត្តេយ្យសិក្សាសហគមន៍ ត្រូវបានប្រើប្រាស់ជាចំណុចផ្តើមសម្រាប់ការអប់រំពហុភាសា។ ឯកសារបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើង ដើម្បីបណ្តុះបណ្តាលគ្រូអំពីជំនាញអនុវត្តកម្មវិធីអប់រំពហុភាសា ដែលប្រើប្រាស់ភាសាជនជាតិដើមភាគតិច ជាមួយនឹងការប្រើប្រាស់ភាសាខ្មែរជាបណ្តើរៗ។ កម្មវិធីនេះត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងថ្នាក់មត្តេយ្យសិក្សាសហគមន៍សាកល្បងចំនួន ២០ថ្នាក់ នៅក្នុងឆ្នាំ ២០១១ និងក្រោយមក បានបង្កើនដល់ ២៣ថ្នាក់ នៅក្នុងឆ្នាំ ២០១៣។ ចាប់តាំងពីចាប់ផ្តើមអនុវត្តដំបូងមក កម្មវិធីនេះបានផ្តល់លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ ដល់កុមារជាង ៤០០នាក់ មកពីក្រុមនិយាយភាសាភាគតិចជារៀងរាល់ឆ្នាំ។

រូបភាពទី ១ ៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សា ២០១០-២០១១ និង ២០១៣-២០១៤




៤ នៅក្នុងខេត្តភាគឦសានទាំង ៥ ដែលការអប់រំពហុភាសាកំពុងត្រូវបានអនុវត្ត។ វឌ្ឍនភាពនេះសំដៅដល់វឌ្ឍនភាពលើអត្រាពិតនៃការសិក្សានៅបឋមសិក្សា អត្រាត្រួតថ្នាក់បឋមសិក្សា និងអត្រាបោះបង់ចោលការសិក្សានៅបឋមសិក្សា ធៀបនឹងទិន្នន័យនៅថ្នាក់ជាតិ។ ទិន្នន័យអត្រាពិតនៃការសិក្សានៅបឋមសិក្សា នៅថ្នាក់ខេត្ត បង្ហាញឱ្យឃើញពីវឌ្ឍនភាព ក្នុងគ្រប់ខេត្តទាំងអស់ លើកលែងតែខេត្តស្ទឹងត្រែងចេញ។ ខេត្តរតនគិរី មានកំណើនខ្ពស់ជាងគេរហូតដល់ ២០ ភាគរយ។ ជាការពិត ខេត្តទាំង ៤ មានកំណើនលើសពីអត្រាមធ្យមនៅថ្នាក់ជាតិ។ ជាការសំខាន់ ដែលត្រូវទទួលស្គាល់ថា ខេត្តទាំង ៤ មានអត្រាសិក្សាទាបជាងអត្រាមធ្យមនៅថ្នាក់ជាតិ នៅក្នុងឆ្នាំសិក្សា ២០១០-២០១១ ដូច្នេះវាមានភាពងាយស្រួលក្នុងការប្រៀបធៀបអំពីវឌ្ឍនភាពដែលខេត្តទាំងនេះសម្រេចបាន។

រូបភាពទី ២ ៖ អត្រាត្រួតថ្នាក់នៅបឋមសិក្សា ឆ្នាំសិក្សា ២០១០-២០១១ និង ២០១៣-២០១៤



រូបភាពទី ២ បង្ហាញពីការថយចុះនូវអត្រាត្រួតថ្នាក់ នៅក្នុងខេត្តទាំង ៥ ដែលកំពុងអនុវត្តការអប់រំពហុភាសា។ ក្នុងពេលជាមួយគ្នា អត្រាត្រួតថ្នាក់នៅថ្នាក់ជាតិ មានការថយចុះពី ៥,៣ភាគរយ មក៤,៨ភាគរយ។ ប៉ុន្តែ មានការកត់សម្គាល់ថា អត្រា ១៣ភាគរយនៅក្នុងខេត្តស្ទឹងត្រែង និង៩ភាគរយនៅក្នុងខេត្តព្រះវិហារ នៅតែមានកម្រិតខ្ពស់ បើទោះបីជាមានវឌ្ឍនភាពជាទូទៅយ៉ាងណាក៏ដោយ។ ខណៈពេលដែលគេមិនអាចចាត់ទុកការប្រែប្រួលជាវិជ្ជមានទាំងនេះ ថាកើតឡើង ដោយសារតែកម្មវិធីអប់រំពហុភាសាតែឯងនោះ (ដែលនៅមានវិសាលភាពតូចនៅឡើយ) គេអាចសន្មត់ថា បច្ចុប្បន្ននេះ មានកុមារចំនួន ៣៣៣២នាក់ កំពុងរៀនសូត្រ នៅក្នុងបរិយាកាសដែលមានភាពពាក់ព័ន្ធជាងមុន និងប្រើប្រាស់ភាសាដែលពួកគេចេះ បានផ្តល់លទ្ធភាពឱ្យពួកគេអាចរៀនឡើងថ្នាក់ ក្នុងកម្រិតបឋមសិក្សាកាន់តែមានប្រសិទ្ធភាព។

## ៨. ការធ្វើឱ្យកម្មវិធីអប់រំពហុភាសាមាននិរន្តរភាព

កម្មវិធីអប់រំដោយប្រើប្រាស់ភាសាកំណើតធ្វើជាភាសាគោល បានចាប់ផ្តើមនៅស្ទើរតែគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោក។ គួរឱ្យសោកស្តាយ កម្មវិធីជាច្រើន ក្នុងចំណោមកម្មវិធីទាំងនេះពុំមាននិរន្តរភាពឡើយ។ ជារឿយៗ កម្មវិធីទាំងនេះត្រូវបញ្ចប់ទៅវិញ ហើយសិស្សមិនបានសម្រេចនូវគោលដៅអប់រំរយៈពេលវែងរបស់ខ្លួនឡើយ។ ក្នុងនាមជាអ្នកឯកទេសផ្នែកអប់រំ យើងប្រហែលជាត្រូវសួរសំណួរខាងក្រោម ៖

- ហេតុអ្វីបានជាកម្មវិធីមួយចំនួនបរាជ័យ និងកម្មវិធីផ្សេងទៀតនៅតែដំណើរការបាន?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីឱ្យកម្មវិធីរបស់យើងទទួលបានជោគជ័យ និងមាននិរន្តរភាព?

ការសិក្សាលើកម្មវិធីនានាដែលមាននិរន្តរភាព នៅក្នុងរយៈពេលមួយ បង្ហាញថា កម្មវិធីទាំងនោះមានលក្ខណៈ ដូចគ្នាជាច្រើន ៖

- កម្មវិធីនេះចាប់ផ្តើម ដោយសារតែមនុស្សនៅក្នុងសហគមន៍ចង់បានវា។ ពួកគេជឿថា កម្មវិធីនេះនឹងជួយឱ្យពួកគេសម្រេចគោលដៅជាក់លាក់ ឬបំពេញតម្រូវការជាក់លាក់របស់ពួកគេ។
- សមាជិកសហគមន៍ដឹកនាំការរៀបចំផែនការ ការអនុវត្ត និងការរក្សាកម្មវិធីរបស់ពួកគេឱ្យនៅគង់វង្ស។
- នៅពេលដែលកម្មវិធីនេះត្រូវបានបង្កើត ប្រជាជននៅក្នុងសហគមន៍ (ជាពិសេសសិស្ស) យល់ឃើញថា កម្មវិធីនេះពិតជាបានជួយពួកគេ ក្នុងការសម្រេចតាមគោលដៅរបស់ពួកគេ និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគេពិតប្រាកដមែន។
- សហគមន៍ជាអ្នកទទួលខុសត្រូវលើកម្មវិធីនេះ។ ពួកគេជាអ្នកធ្វើសេចក្តីសម្រេចចិត្តអំពីកម្មវិធីនេះ ពួកគេធ្វើការវាយតម្លៃកម្មវិធី និងធ្វើការសម្រេចចិត្តថាតើមានការផ្លាស់ប្តូរអ្វីខ្លះ ដែលចាំបាច់ត្រូវធ្វើ។
- កម្មវិធីនេះមានទំនាក់ទំនងជាមួយនឹងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីឱ្យប្រជាជនក្នុងសហគមន៍នៅតែអាចបន្តទទួលបានគំនិត ជំនាញ និងព័ត៌មានថ្មីៗដែលមានប្រយោជន៍ នៅពេលដែលពួកគេរៀនអាន និងសរសេរ។

- កម្មវិធីនេះផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងកម្មវិធីអប់រំក្នុងប្រព័ន្ធ និង/ឬក្រៅប្រព័ន្ធផ្សេងទៀត ទាំងក្នុងទាំងក្រៅសហគមន៍។ នៅពេលដែលសិស្សបញ្ចប់កម្មវិធីក្នុងសហគមន៍ ពួកគេអាចបន្តការអប់រំរបស់ខ្លួនបាន ប្រសិនបើពួកគេចង់។ ឧទាហរណ៍ សិស្សដែលរៀនចប់កម្មវិធីអប់រំកម្រិតបឋមសិក្សានៅក្នុងភូមិរបស់ពួកគេ អាចបន្តទៅរៀនក្នុងប្រព័ន្ធអប់រំមធ្យមសិក្សាបាន។
- កម្មវិធីនេះទទួលបានការគាំទ្រចាំបាច់ពីខាងក្រៅសហគមន៍ផងដែរ ដូចជា ពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សកលវិទ្យាល័យ វិស័យធុរកិច្ច និងអ្នកផ្តល់ជំនួយ ក៏ដូចជាពីស្ថាប័នផ្សេងទៀត (ដូចជា សមាគមភាសា និងវប្បធម៌ ជាដើម)។

## ៩. យុទ្ធសាស្ត្រ

បើទោះបីជាលទ្ធភាពទទួលបានការអប់រំ និងគុណភាពនៃការអប់រំ មានការរីកចម្រើនជាទូទៅ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ការអប់រំនៅតាមបណ្តាខេត្តភាគឦសាន នៅតែជួបប្រទះនឹងបញ្ហាប្រឈម និងឧបសគ្គជាច្រើន។ បញ្ហាប្រឈមទាំងនេះ រួមមាន ចម្ងាយពីផ្ទះទៅសាលារៀន សហគមន៍ពុំរស់នៅប្រមូលផ្តុំគ្នា ប៉ុន្តែរស់នៅរាយប៉ាយពីគ្នា កង្វះគ្រូដែលមានសមត្ថភាព ការបោះបង់ការសិក្សាមានកម្រិតខ្ពស់ក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ និងបញ្ហាអាហារូបត្ថម្ភ ។ល។

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសានេះ នឹងចូលរួមចំណែកយ៉ាងធំធេងដល់ការដោះស្រាយបញ្ហាប្រឈមដែលលើកឡើងខាងលើ តាមរយៈយុទ្ធសាស្ត្រខាងក្រោមដែលត្រូវបានលើកយកមកពិភាក្សា និងទទួលបានការឯកភាពពីអ្នកចូលរួមក្នុងសិក្ខាសាលាមកពីខេត្តទាំង ៥ [5] ។

### ៩.១. ការកសាងសមត្ថភាព ជាពិសេស ដល់គ្រូ និងការបណ្តុះបណ្តាលគ្រូ

- ជ្រើសរើសគរុសិស្ស ពីសហគមន៍ជនជាតិដើមភាគតិច ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសថ្នាក់ជាតិ (ផ្តល់អាទិភាពពិសេស) ដើម្បីឱ្យចូលរៀននៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងក្លាយជាគ្រូបង្រៀនរបស់រដ្ឋ ដែលនៅទីនោះ ពួកគេនឹងទទួលបានការបណ្តុះបណ្តាលបន្ថែមអំពីការអប់រំពហុភាសា សម្រាប់ធ្វើជាយុទ្ធសាស្ត្ររយៈពេលវែង។
- បញ្ជ្រាបមុខងាររបស់គ្រូអប់រំពហុភាសាតាមសហគមន៍ តាមរយៈការផ្តល់ការទទួលស្គាល់ជាផ្លូវការដល់គ្រូទាំងឡាយណា ដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនៃស្តង់ដារអប្បបរមាមួយចំនួន និងដល់ការបណ្តុះ

[5] ខេត្តព្រះវិហារ បានចូលរួមយ៉ាងសកម្ម នៅក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសានេះ ប៉ុន្តែនៅមិនទាន់សម្រេចចិត្តអនុវត្តការអប់រំពហុភាសានៅឡើយ។

បណ្តាលដល់ពួកគេ នៅពេលដែលពួកគេក្លាយជាគ្រូរង្គ។ បញ្ជាក់ឱ្យបានច្បាស់ពីលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់អាហារូបករណ៍ដល់សិស្ស នៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា និងធ្វើការពង្រាយគ្រូទៅកាន់តំបន់ ឬសាលារៀនដាច់ស្រយាលសាជាថ្មី។

- ផ្តល់ការអភិវឌ្ឍ និងការតម្រង់ទិសវិជ្ជាជីវៈដល់គ្រូអប់រំពហុភាសា ទាំងគ្រូកិច្ចសន្យានិងគ្រូរង្គ ដោយផ្តោតជាពិសេសលើការអភិវឌ្ឍ និងការលើកកម្ពស់ជំនាញបន្ថែមទៀតដល់គ្រូបង្រៀនអំពីវិធីសាស្ត្រ និងបច្ចេកទេសបង្រៀនពហុភាសា។
- ផ្តល់ការបំប៉ន និងការអភិវឌ្ឍវិជ្ជាជីវៈបន្ថែមទៀត ដល់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អំពីការអប់រំពហុភាសា (ការអប់រំកុមារតូច/មត្តេយ្យសិក្សា និងសាលាបឋមសិក្សា)។
- រៀបចំដំណើរទស្សនកិច្ចសិក្សាក្នុងប្រទេស (សម្រាប់គ្រូ និងមន្ត្រីមកពីខេត្ត "ដែលទើបចាប់ផ្តើមអនុវត្តការអប់រំពហុភាសា" ទៅកាន់ខេត្តដែលមានការអនុវត្តការអប់រំពហុភាសាយូរមកហើយ) និងទៅខាងក្រៅប្រទេស (សម្រាប់ថ្នាក់ដឹកនាំសំខាន់ៗនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៃក្រសួងអប់រំ យុវជន និងកីឡា ទៅកាន់ប្រទេសនៅអាស៊ានដទៃទៀត ដែលបានអនុវត្តការអប់រំពហុភាសាបានយ៉ាងល្អកន្លងមក ដូចជា ប្រទេសហ្វីលីពីនជាដើម)។

## ៤.២. ផ្តល់សម្ភារបង្រៀន និងរៀន

- បោះពុម្ពផ្សាយសៀវភៅសិក្សា សៀវភៅគ្រូ និងឯកសារបង្រៀនផ្សេងទៀត និងជំរុញឱ្យមានការចូលរួមពីគ្រូ និងគរុសិស្សដែលធ្វើការងារពាក់ព័ន្ធនឹងការអប់រំពហុភាសា (មកពីជនជាតិភាគតិច) នៅក្នុងការរៀបចំឯកសារភាសា ដែលមានខ្លឹមសារពាក់ព័ន្ធនឹងជីវភាពរស់នៅក្នុងមូលដ្ឋាន។ ការងារនេះគួរមានដាក់បញ្ចូលការពិនិត្យឡើងវិញលើឯកសារបច្ចុប្បន្ននេះ ដោយមានការផ្តល់អនុសាសន៍សម្រាប់ធ្វើការកែលម្អ និងធានាយ៉ាងណាឱ្យថ្នាក់រៀនអប់រំពហុភាសាទាំងអស់ មានឯកសារពាក់ព័ន្ធក្នុងចំនួនគ្រប់គ្រាន់ និងធ្វើការបោះពុម្ពឯកសារដែលមានស្រាប់ នៅក្នុងករណីចាំបាច់។

## ៤.៣. ការសម្របសម្រួល ទិន្នន័យនិងព័ត៌មាន ការពិនិត្យតាមដាន និងការវាយតម្លៃ

- បង្កើតនូវតួនាទីសហការគ្នា រវាងនាយកដ្ឋានអប់រំកុមារតូច និងនាយកដ្ឋានបឋមសិក្សា ក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសានេះ ដើម្បីឱ្យការអប់រំពហុភាសានៅកម្រិតអប់រំកុមារតូច និងបឋមសិក្សា ត្រូវបានដាក់បញ្ចូលជាមួយគ្នា និងធានាឱ្យមានការឆ្លងភូមិសិក្សាដោយរលូនរបស់សិស្សដែលទទួលបានការអប់រំពហុភាសា ពីការអប់រំកុមារតូចទៅការអប់រំកម្រិតបឋមសិក្សា។

- ដាក់បញ្ចូលស្ថិតិដែលអាចជឿទុកចិត្តបានអំពីកុមារជនជាតិដើមភាគតិច និងទិន្នន័យអប់រំពហុភាសា ទៅក្នុងស្ថិតិជាតិ (EMIS)។
- រៀបចំការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តការអប់រំពហុភាសា ដូចជា រៀបចំកិច្ចប្រជុំជាមួយសហគមន៍ និងគ្រូជាប់កិច្ចសន្យា ជារៀងរាល់ឆមាស។

## ៩.៤. ការពង្រីកការផ្តល់ការអប់រំពហុភាសា

- ពង្រីកការផ្តល់ការអប់រំពហុភាសា និងការបញ្ចូលសាលាពហុភាសាឱ្យទៅជាសាលាសាធារណៈ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំផែនការសកម្មភាពដើម្បីបញ្ចូលសាលាសហគមន៍ទៅជាសាលាសាធារណៈ ដែលគ្រប់គ្រងនឹងចាត់ចែងការងារ ដូចសាលាសាធារណៈដ៏ទៃទៀត ដោយពង្រឹងនិងពង្រីកការផ្តល់សេវាអប់រំ ដល់គ្រប់កុមារជនជាតិដើមភាគតិច បានចូលរៀន និងរៀនចប់ថ្នាក់ក្នុងកម្រិតបឋមសិក្សាប្រកបដោយគុណភាព។

***ការធ្វើចំណោលចំនួនសាលារៀនដែលផ្តល់ការអប់រំពហុភាសានៅមត្តេយ្យ***

| ខេត្ត | សាលារៀន 2014-15 | សាលារៀនថ្មីៗ*** 2015-16 | 2016-17 | 2017-18 | 2018-19 | សាលារៀនសរុប | កើន % |
|---|---|---|---|---|---|---|---|
| រតនគិរី | 14 | 10 | 0 | 0 | 0 | 24 | 71% |
| មណ្ឌលគិរី | 4 | 7 | 0 | 0 | 0 | 11 | 175% |
| ស្ទឹងត្រែង | 6 | 7 | 0 | 0 | 0 | 13 | 117% |
| ក្រចេះ | 6 | 6 | 0 | 0 | 0 | 12 | 100% |
| ព្រះវិហារ | 4 | 0 | 0 | 0 | 0 | 4 | 0% |
| សរុប | 34* | 30 | 0 | 0 | 0 | 64** | 88% |

- *របាយការណ៍អនុវិស័យអប់រំកុមារតូច
- **ក្របខ័ណ្ឌលទ្ធផលអប់រំកុមារតូចកំណត់ចំណុចដៅ១០សាលាក្នុងមួយឆ្នាំ តែចំណុចដៅចុងក្រោយឆ្នាំ២០១៨គឺ៦៨សាលាដូចគ្នា។
- ***ចំនួនសាលាមិនមែនជាចំនួនបូកបន្តទេ។ មានន័យថានៅតែចាំបាច់ត្រូវការការជួយគាំទ្រដល់សាលាទាំងនោះ ទោះជាចំនួនសាលាស្មើសូន្យក៏ដោយ។

***ការធ្វើចំណោលចំនួនសិស្សដែលផ្តល់ការអប់រំពហុភាសានៅមត្តេយ្យ***

| ខេត្ត | សិស្ស 2014-15 | សិស្សថ្មី 2015-16 | 2016-17 | 2017-18 | 2018-19 | សិស្សសរុប | កើន % |
|---|---|---|---|---|---|---|---|
| រតនគិរី | 105 | 210 | 0 | 0 | 0 | 315 | 200% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មណ្ឌលគិរី | 177 | 147 | 0 | 0 | 0 | 324 | 83% |
| ស្ទឹងត្រែង | 176 | 147 | 0 | 0 | 0 | 323 | 84% |
| ក្រចេះ | 116 | 126 | 0 | 0 | 0 | 242 | 109% |
| ព្រះវិហារ | 133 | 0 | 0 | 0 | 0 | 133 | 0% |
| សរុប | 707 | 630 | 0 | 0 | 0 | 1337 | 89% |

### *ការធ្វើចំណោលចំនួនគ្រូដែលផ្តល់ការអប់រំពហុភាសានៅមត្តេយ្យ*

| ខេត្ត | ចំនួនគ្រូ | គ្រូថ្មី | | | | ចំនួនគ្រូ | កើន % |
|---|---|---|---|---|---|---|---|
| | 2014-15 | 2015-16 | 2016-17 | 2017-18 | 2018-19 | សរុប | |
| រតនគិរី | 14 | 10 | 0 | 0 | 0 | 24 | 71% |
| មណ្ឌលគិរី | 4 | 7 | 0 | 0 | 0 | 11 | 175% |
| ស្ទឹងត្រែង | 6 | 7 | 0 | 0 | 0 | 13 | 117% |
| ក្រចេះ | 6 | 6 | 0 | 0 | 0 | 12 | 100% |
| ព្រះវិហារ | 4 | 0 | 0 | 0 | 0 | 4 | 0% |
| សរុប | 34 | 30 | 0 | 0 | 0 | 64 | 88% |

### *ការធ្វើចំណោលចំនួនសាលារៀនដែលផ្តល់ការអប់រំពហុភាសានៅបឋមសិក្សា*

| ខេត្ត | សាលារៀន | សាលារៀនថ្មីៗ | | | | សាលារៀន | កើន % |
|---|---|---|---|---|---|---|---|
| | 2014-15 | 2015-16 | 2016-17 | 2017-18 | 2018-19 | សរុប | |
| រតនគិរី | 20 | 12 | 2 | 2 | 2 | 38 | 90% |
| មណ្ឌលគិរី | 12 | - | 10 | 10 | 10 | 42 | 250% |
| ស្ទឹងត្រែង | 9 | 0 | 0 | 0 | 0 | 9 | 0% |
| ក្រចេះ | 13 | 0 | 2 | 2 | 2 | 19 | 46% |
| ព្រះវិហារ* | | | | | | | 0% |
| សរុប | **54** | **12** | **14** | **14** | **14** | **108** | 100% |

** Preah Vihear* pending result of community mapping*

### *ការធ្វើចំណោលចំនួនសិស្ស នៅសាលារៀនដែលផ្តល់ការអប់រំពហុភាសានៅបឋមសិក្សា*

| ខេត្ត | សិស្ស | សិស្សថ្មី | | | | សិស្ស សរុប | កើន % |
|---|---|---|---|---|---|---|---|
| | 2014-15 | 2015-16 | 2016-17 | 2017-18 | 2018-19 | | |
| រតនគិរី | 2,029 | 540 | 630 | 720 | 270 | 4,189 | 106.5% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មណ្ឌលគិរី | 524 | 0 | 276 | 600 | 700 | 2,100 | 300.8% |
| ស្ទឹងត្រែង | 914 | 0 | 0 | 0 | 0 | 914 | 0% |
| ក្រចេះ | 577 | 0 | 450 | 120 | 180 | 1,327 | 130% |
| ព្រះវិហារ* | | | | | | | 0% |
| **សរុប** | **3,572** | **540** | **1,356** | **1,440** | **1,150** | **8,530** | **125.6%** |

** Preah Vihear* pending result of community mapping*

***ការធ្វើចំណោលចំនួនគ្រូ នៅសាលារៀនដែលផ្តល់ការអប់រំពហុភាសានៅបឋមសិក្សា***

| ខេត្ត | ចំនួនគ្រូ | គ្រូថ្មី | | | | ចំនួនគ្រូ | កើន % |
|---|---|---|---|---|---|---|---|
| | 2014-15 | 2015-16 | 2016-17 | 2017-18 | 2018-19 | សរុប | |
| រតនគិរី | 88 | 12 | 14 | 16 | 6 | 136 | 54.5% |
| មណ្ឌលគិរី | 26 | 0 | 25 | 0 | 25 | 76 | 192% |
| ស្ទឹងត្រែង | 37 | 0 | 0 | 0 | 0 | 37 | 0% |
| ក្រចេះ | 23 | 0 | 5 | 13 | 10 | 51 | 121.7% |
| ព្រះវិហារ* | | | | | | | 0% |
| **សរុប** | **174** | **12** | **44** | **29** | **41** | **300** | **72.4%** |

** Preah Vihear* pending result of community mapping*

៩.៥. ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន

- ធានាយ៉ាងណាឱ្យមានធនធាន និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីអនុវត្តផែនការនេះ នៅថ្នាក់ជាតិ។
- សាងសង់អន្តេវាសិកដ្ឋាននៅអនុវិទ្យាល័យ សម្រាប់សិស្សមកពីសហគមន៍ជនជាតិភាគតិច។

៩.៦. សាលារៀនសហគមន៍

- ធានាថា សាលារៀនសហគមន៍ទាំងអស់ត្រូវបានផ្លាស់ប្តូរទៅជាសាលារៀនរដ្ឋ។

## ១០. បញ្ហាទូទៅដែលត្រូវដោះស្រាយ

១. កំណត់ពីចំនួនកុមារជនជាតិដើមភាគតិចដែល

- បានចុះឈ្មោះចូលរៀនក្នុងសាលារៀន
- បានបោះបង់ចោលការសិក្សា
- មិនដែលចុះឈ្មោះចូលរៀន។

២. រៀបចំយុទ្ធសាស្ត្រសម្រាប់បង្កើនគុណភាពសាលារៀន និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន។

៣. ការបណ្តុះបណ្តាលអំពីកិច្ចពិគ្រោះយោបល់សហគមន៍ ការចូលរួមរបស់សហគមន៍ និងការកសាងសមត្ថភាពរបស់គណៈកម្មការទ្រទ្រង់សាលារៀន។

៤. ការបំប៉នអំពីការអប់រំពហុភាសា ដល់គ្រូបង្រៀន ដែលធ្វើការងារតាមសាលារៀនដែលផ្តល់ការអប់រំពហុភាសា។

៥. រៀបចំសិក្ខាសាលាតាមខេត្តនីមួយៗ ដើម្បីរៀបចំផែនទីបង្ហាញពីកុមារជនជាតិដើមភាគតិចដែលនៅក្នុងនិងក្រៅសាលារៀន។

រៀបចំបញ្ជីត្រួតពិនិត្យនៃជំហាននានា ដែលត្រូវអនុវត្តនៅពេលធ្វើផែនការពង្រីកសាលាបឋមសិក្សា/សាលាមត្តេយ្យសិក្សាអប់រំពហុភាសាថ្មីៗទៀត។ បញ្ជីត្រួតពិនិត្យនេះអាចដាក់បញ្ចូលចំណុចផ្សេងៗ ដូចជា ការពិគ្រោះយោបល់ជាមួយសហគមន៍ និងការលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ ការអង្កេតអំពីភាសានៅក្នុងសហគមន៍ និងការជ្រើសរើសគ្រូ។

## ១១. គុណភាព ការពិនិត្យតាមដាន និងការវាយតម្លៃ

ដើម្បីធានាឱ្យមានការអនុវត្តកម្មវិធីអប់រំពហុភាសាប្រកបដោយគុណភាព នៅក្នុងប្រទេសកម្ពុជា នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើតការពិនិត្យតាមដានមួយលើសាលារៀនដែលផ្តល់ការអប់រំពហុភាសា ដែលនឹងមានដាក់បញ្ចូលការស្រាវជ្រាវ និងការវាយតម្លៃសិស្សជាបន្ត។ លទ្ធផលនៃការងារនេះ នឹងផ្តល់ជាព័ត៌មានទៀងទាត់ដល់អ្នកពាក់ព័ន្ធ គណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតានិងគ្រូបង្រៀន មន្ទីរអប់រំ និងការិយាល័យអប់រំស្រុក ដែលនឹងផ្តល់នូវព័ត៌មានសំខាន់ៗអំពីឱកាសកែលម្អគុណភាពកម្មវិធីជាបន្ត។

# ១២. ស្ថិតិជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា

## ១២.១. វិសាលភាពនៃការអប់រំពហុភាសា បែងចែកតាមខេត្ត

| ខេត្ត | ចំនួនជនជាតិដើមភាគតិច ប៉ាន់ស្មាន | ចំនួនសាលារៀនផ្ដល់ការអប់រំពហុភាសាបច្ចុប្បន្ន | ចំនួនគ្រូសហគមន៍អប់រំពហុភាសា បច្ចុប្បន្ន | ចំនួនគ្រូជនជាតិដើមភាគតិចមានសមត្ថភាព ដែលកំពុងបង្រៀន នៅតាមសាលារៀនដែលមិនផ្ដល់ការអប់រំពហុភាសា |
|---|---|---|---|---|
| រតនគិរី | 117,129 | 19 | 60 | |
| មណ្ឌលគិរី | 41,964 | 12 | 7 | |
| ស្ទឹងត្រែង | 4,912 | 9 | 37 | |
| ក្រចេះ | 13,141 | 13 | 23 | |
| ព្រះវិហារ | 6,136 | 2 | 2 | |
| **សរុប** | **183,283** | **55** | **129** | |

## ១២.២. កុមារជនជាតិដើមភាគតិច និងស្ថានភាពនៃការអប់រំរបស់ពួកគេ

| ខេត្ត | ចំនួនប្រជាជនអាយុ ៣-១៧ ឆ្នាំសរុប ដែលត្រូវបានព្យាករក្នុង ខេត្ត (២០១៤) | ចំនួនប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិច អាយុ ៣-១៧ ឆ្នាំ (២០១៤) | កុមារជនជាតិដើមភាគតិច (៣-១៧ ឆ្នាំ) រៀនក្នុងសាលា (អប់រំពហុភាសា និងមិនមែនអប់រំពហុភាសា) (២០១៤-១៥) | % នៃកុមារជនជាតិដើមភាគតិច រៀនក្នុងសាលា (២០១៤-១៥) | កុមារជនជាតិដើមភាគតិច (៣-១៧ ឆ្នាំ) រៀន ក្នុងសាលាដែល មិនផ្តល់ការអប់រំពហុភាសា | % នៃកុមារជនជាតិដើមភាគតិច រៀន ក្នុងសាលាដែលមិនផ្តល់ការអប់រំពហុភាសា (២០១៤-១៥) | | ចំនួនប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិចក្រៅសាលា (២០១៤) | | % ប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិច ក្រៅសាលា (២០១៤) | កុមារអាយុ ៣-១៧ ឆ្នាំ ដែលមានភាសាកំណើតមិនមែនជាភាសាខ្មែរ ដែលមិនដែលបានទៅរៀន[6] |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | *គិតជាភាគរយនៃកុមារជនជាតិភាគតិចទាំងអស់* | *គិតជា ភាគរយនៃ កុមារជន ជាតិភាគតិច ដែលកំពុង រៀនតាម សាលា* | | | | |
| ប្រភព | វិទ្យាស្ថានជាតិស្ថិតិ | ការប៉ាន់ប្រមាណផ្អែកទៅតាម ទិន្នន័យរបស់ វិទ្យាស្ថានជាតិស្ថិតិ | ទិន្នន័យពីមន្ទីរអប់រំ | ទិន្នន័យពីមន្ទីរអប់រំ | ទិន្នន័យពីមន្ទីរអប់រំ | | | | | | |
| ក្រចេះ | 126,211 | 19,184 | 7,412 | 39% | 6,647 | 35% | 90% | 11,772 | 6,015 | 61% | 51% |
| មណ្ឌលគិរី | 26,436 | 16,285 | 7,408 | 45% | 6,708 | 41% | 91% | 8,877 | 4,202 | 55% | 57% |
| រតនគិរី | 61,539 | 43,139 | 17,321 | 40% | 2,029 | 5% | 12% | 25,818 | 11,327 | 60% | 72% |
| ស្ទឹងត្រែង | 43,691 | 3,845 | 1,088 | 28% | 8 | 0% | 1% | 2,757 | 1,405 | 72% | 60% |
| **សរុប** | **257,877** | **82,452** | **33,229** | **40%** | **15,392** | **19%** | **46%** | **49,223** | | **60%** | |

**ការសន្និដ្ឋានអំពីទិន្នន័យ ៖**

[6] ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨ "ការចូលរៀន" ទំព័រ ៦១-៦២

- ដោយសារតែទិន្នន័យមិនអាចរកបាន ចំណោលប្រជាជនសម្រាប់ឆ្នាំ ២០១៤ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ត្រូវបានប្រើប្រាស់នៅក្នុងតារាងនេះ
- ការប៉ាន់ប្រមាណពីចំនួនកុមារជនជាតិដើមភាគតិចអាយុ ៣-១៧ ឆ្នាំ ត្រូវបានគណនាចេញពីចំណោលប្រជាជនរបស់វិទ្យាស្ថានជាតិស្ថិតិជាមួយនឹងភាគរយនៃជនជាតិដើមភាគតិច នៅក្នុង "ការវិភាគលើការទទួលបានការអប់រំរបស់កុមារ ផ្អែកទៅតាមជំរឿនទូទៅនៃប្រជារាស្ត្រក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨"
- តួលេខកុមារក្នុងសាលាជាក់ស្តែង ត្រូវបានផ្តល់ដោយមន្ទីរអប់រំ នៅតាមខេត្តពាក់ព័ន្ធ
- ទិន្នន័យកុមារជនជាតិដើមភាគតិចក្រៅសាលា គឺជាការគណនាពីចំនួនជនជាតិដើមភាគតិចសរុប ដកនឹងចំនួនជនជាតិដើមភាគតិចក្នុងសាលា ដែលផ្តល់ដោយមន្ទីរអប់រំ

## ១២.៣. កុមារជនជាតិដើមភាគតិច និងស្ថានភាពនៃការអប់រំរបស់ពួកគេ នៅកម្រិតមត្តេយ្យសិក្សា

| ខេត្ត | ចំនួនប្រជាជនអាយុ ៣-៥ឆ្នាំសរុបដែលត្រូវបានព្យាករក្នុងខេត្ត (២០១៤) | ចំនួនប៉ាន់ស្មាន នៃកុមារជនជាតិ ដើមភាគតិច អាយុ ៣-៥ ឆ្នាំ (២០១៤) | កុមារជនជាតិដើមភាគតិច(៣-៥ឆ្នាំ)រៀនក្នុងសាលា(អប់រំពហុភាសា និងមិនមែនអប់រំពហុភាសា) (២០១៤/១៥) | % នៃកុមារជនជាតិដើមភាគតិច រៀនក្នុងសាលា មត្តេយ្យសិក្សា (២០១៤/១៥) | កុមារជនជាតិដើមភាគតិច (៣-៥ ឆ្នាំ) រៀនក្នុងសាលាដែលមិនផ្តល់ការអប់រំពហុភាសា | % នៃកុមារជនជាតិដើមភាគតិចរៀនក្នុងសាលាដែលមិនផ្តល់ការអប់រំពហុភាសា (២០១៤/១៥) | | ចំនួនប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិច ក្រៅសាលា មត្តេយ្យ (២០១៤) | %ប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិច ក្រៅសាលាមត្តេយ្យ (២០១៤) |
|---|---|---|---|---|---|---|---|---|---|
| | | | | | | *គិតជាភាគរយ នៃកុមារជន ជាតិភាគតិច ទាំងអស់* | *គិតជាភាគរយនៃកុមារជនជាតិភាគតិចដែលកំពុងរៀនតាម សាលា* | | |
| ប្រភព | វិទ្យាស្ថានជាតិស្ថិតិ | ការប៉ាន់ប្រមាណផ្អែកតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ | ទិន្នន័យពីមន្ទីរអប់រំ | ទិន្នន័យពីមន្ទីរអប់រំ | ទិន្នន័យពីមន្ទីរ អប់រំ | | | | |
| ក្រចេះ | 24,933 | 3,790 | 171 | 5% | - | 0% | 0% | 3,619 | 95% |
| មណ្ឌលគិរី | 4,905 | 3,021 | 537 | 18% | 361 | 12% | 67% | 2,484 | 82% |
| រតនគិរី | 10,551 | 7,396 | 105 | 1% | 105 | 1% | 100% | 7,291 | 99% |
| ស្ទឹងត្រែង | 8,155 | 718 | 184 | 26% | 8 | 1% | 4% | 534 | 74% |
| **សរុប** | **48,544** | **14,925** | **997** | **0** | **474** | **3%** | **48%** | **13,928** | **93%** |

## ១២.៤. កុមារជនជាតិដើមភាគតិច និងស្ថានភាពនៃការអប់រំរបស់ពួកគេ នៅកម្រិតបឋមសិក្សា

| ខេត្ត | ចំនួនប្រជាជន អាយុ ៦-១៧ ឆ្នាំសរុប ដែលត្រូវបានព្យាករក្នុងខេត្ត (២០១៤) | ចំនួនប៉ាន់ស្មាន នៃកុមារជនជាតិ ដើមភាគតិច អាយុ ៦-១៧ ឆ្នាំ (២០១៤) | កុមារជនជាតិដើមភាគតិច មិនគិតពីអាយុ ដែលរៀនក្នុងសាលាបឋមសិក្សា (អប់រំពហុភាសា និងមិនមែនអប់រំពហុភាសា) (២០១៤/១៥) | % នៃកុមារជនជាតិ ដើមភាគតិច រៀនក្នុងសាលាបឋមសិក្សា (២០១៤/១៥) | កុមារជនជាតិដើមភាគតិច ដោយមិនគិតអាយុ រៀនក្នុងសាលា ដែលមិនផ្តល់ការអប់រំពហុភាសា | % នៃកុមារជនជាតិដើមភាគតិច រៀនក្នុងសាលាដែលមិនផ្តល់ ការអប់រំពហុភាសា (២០១៤/១៥) | | ចំនួនប៉ាន់ ស្មាន នៃកុមារ ជនជាតិដើម ភាគតិចក្រៅសាលា (២០១៤) | % ប៉ាន់ស្មាននៃកុមារជនជាតិដើមភាគតិចក្រៅសាលា (២០១៤) |
|---|---|---|---|---|---|---|---|---|---|
| | | | | | | *គិតជាភាគរយ នៃកុមារជនជាតិដើមភាគតិចទាំងអស់* | *គិតជា ភាគរយនៃ កុមារជន ជាតិដើមភាគតិច ដែលកំពុងរៀនតាម សាលា* | | |
| ប្រភព | វិទ្យាស្ថានជាតិស្ថិតិ | ការប៉ាន់ប្រមាណផ្អែកទៅតាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ | ទិន្នន័យពីមន្ទីរអប់រំ | ទិន្នន័យពីមន្ទីរអប់រំ | ទិន្នន័យពីមន្ទីរអប់រំ | | | | |
| ក្រចេះ | 101,278 | 15,394 | 7,171 | 47% | 6,647 | 43% | 93% | 8,223 | 53% |
| មណ្ឌលគិរី | 21,531 | 13,263 | 6,871 | 52% | 6,347 | 48% | 92% | 6,392 | 48% |
| រតនគិរី | 50,988 | 35,743 | 17,216 | 48% | 15,187 | 42% | 88% | 18,527 | 52% |
| ស្ទឹងត្រែង | 35,536 | 3,127 | 904 | 29% | - | 0% | 0% | 2,223 | 71% |
| សរុប | 209,333 | 67,527 | 32,162 | 48% | 28,181 | 42% | 88% | 35,365 | 52% |

## ១២.៥. ទិដ្ឋភាពទូទៅនៃការផ្តល់មូលនិធិសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា

| សកម្មភាព | ប្រភពថវិកា | 2015 | 2016 | 2017 | សរុប |
|---|---|---|---|---|---|
| ការបណ្តុះបណ្តាលគ្រូ (បឋមសិក្សា) ៖<br>• វគ្គបណ្តុះបណ្តាលមូលដ្ឋាន<br>• វិក្រឹតការ | CARE (PCTFI) | $90,000 | $90,000 | 90,000 | $270,000 |
| | ក្រសួងអប់រំ យុវជន និង កីឡា | | | | |
| | UNICEF | $200,000 | $200,000 | $200,000 | $600,000 |
| ការបណ្តុះបណ្តាលគ្រូ (អប់រំកុមារតូច) ៖<br>• វគ្គបណ្តុះបណ្តាលមូលដ្ឋាន<br>• វិក្រឹតការ | CARE (PCTFI)<br>UNICEF | $240,000 | | | $240,000 |
| | ក្រសួងអប់រំ យុវជន និង កីឡា | | | | |
| ការបំប៉នគ្រូបង្គោល<br>• បឋមសិក្សា<br>• អប់រំកុមារតូច | CARE (Maitri Trust) | $176,497 | $170,655 | $64,587 | $360,000 |
| ការពិគ្រោះយោបល់ជាមួយសហគមន៍ និងការកសាងសមត្ថភាព<br>• បឋមសិក្សា<br>• អប់រំកុមារតូច | UNICEF | | | | |
| | ក្រសួងអប់រំ យុវជន និង កីឡា | | | | |
| | UNICEF | | | | |

| | | | | | |
|---|---|---|---|---|---|
| ការអង្កេតអំពីភាសាក្នុងសហគមន៍<br>• បឋមសិក្សា<br>• អប់រំកុមារតូច | ក្រសួងអប់រំ យុវជន និង កីឡា | | | | |
| ការពិនិត្យតាមដានសាលារៀន និងការកែលម្អគុណភាព<br>• បឋមសិក្សា<br>• អប់រំកុមារតូច | UNICEF<br>ក្រសួងអប់រំ យុវជន និង កីឡា | $30,000 | $30,000 | $30,000 | $90,000 |
| បៀវត្សរ៍គ្រូ<br>• បឋមសិក្សា<br>• អប់រំកុមារតូច | ក្រសួងអប់រំ យុវជន និង កីឡា<br>UNICEF/CARE<br>ក្រុមប្រឹក្សាឃុំ | $20,000 | | | $20,000 |
| អាហារូបករណ៍សម្រាប់សិស្សមធ្យមសិក្សា | ក្រសួងអប់រំ យុវជន និង កីឡា<br>CARE<br>UNICEF | $60,000 | $60,000 | $60,000 | $180,000 |
| អាហារូបករណ៍សម្រាប់គរុសិស្សសាលាគរុកោសល្យខេត្ត | ក្រសួងអប់រំ យុវជន និង កីឡា<br>CARE<br>UNICEF | $40,000 | $40,000 | $40,000 | $120,000 |
| **ថវិកាកម្មវិធី (PB)** | | | | | |
| សម្ភារៈសម្រាប់សាលាមត្តេយ្យអប់រំពហុភាសា | | | | | |
| ការស្រាវជ្រាវភាសា | | | | | |

| | | | | | |
|---|---|---|---|---|---|
| សាកល្បង ៖ ថ្នាក់អប់រំពហុភាសារយៈពេល ៦ ឆ្នាំ (ថ្នាក់ទី ១-៦) | | | | | |
| ការពង្រីកសាលាអប់រំពហុភាសាទៅកាន់សាលា ដែលមានគ្រូរដ្ឋជាជនជាតិដើមភាគតិច | CARE/Educate A Child | 88,300 | 88,300 | 88,300 | 265,000 |
| ការបំប៉នគ្រូរដ្ឋ ដែលបង្រៀននៅសាលាអប់រំពហុភាសា | | | | | |
| អគារសិក្សា (បន្ទប់រៀន)<br>• បឋមសិក្សា<br>• អប់រំកុមារតូច | | | | | |

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ ប្រវត្តិសង្ខេបនៃការអប់រំពហុភាសានៅក្នុងប្រទេសកម្ពុជា

ការអប់រំពហុភាសា សម្រាប់ជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជា ចាប់ផ្ដើមនៅពាក់កណ្ដាលទសវត្សរ៍ ១៩៩០ នៅពេលដែលអង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជា (ICC) បានចាប់ផ្ដើមការងាររៀបចំប្រព័ន្ធអក្ខរក្រម សម្រាប់ភាសាជនជាតិដើមភាគតិចចំនួន ៥ នៅខេត្តដាច់ស្រយាលភាគឦសាន។ ក្នុងពេលជាមួយគ្នា ICC បានបង្កើតនូវកម្មវិធីអក្ខរកម្មពហុភាសាដែលរៀបចំឡើងសម្រាប់វិស័យអប់រំក្រៅប្រព័ន្ធ ដោយផ្ដោតជាសំខាន់លើអក្ខរកម្មមនុស្សពេញវ័យ។ ការងារភាសាដំបូងៗនេះ មានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងការរៀបចំជាមូលដ្ឋានសម្រាប់អ្នកពាក់ព័ន្ធផ្សេងទៀត សម្រាប់អង្គការមិនមែនរដ្ឋាភិបាល និងចុងក្រោយ សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រីកការអប់រំពហុភាសាទៅក្នុងសហគមន៍ដែលមានចំនួនកើនឡើងជាលំដាប់ និងចូលទៅក្នុងការអប់រំក្នុងប្រព័ន្ធ។

គម្រោងអប់រំកុមារតំបន់ខ្ពង់រាប (HCEP) ត្រូវបានបង្កើតឡើង ជាគម្រោងសាកល្បង នៅក្នុងការអប់រំក្នុងប្រព័ន្ធតាមសាលារៀន ដែលអនុវត្តដោយអង្គការ CARE អន្តរជាតិប្រចាំប្រទេសកម្ពុជា ក្នុងខែ មករា ឆ្នាំ ២០០២ នៅក្នុងខេត្តរតនគិរី។ ចាប់ពីដំបូង គម្រោងរបស់អង្គការ CARE បានជម្រុញឱ្យមានការចូលរួមពីក្រសួងអប់រំ យុវជន និងកីឡា។ តាមពិត គោលបំណងដំបូងមួយ ក្នុងចំណោមគោលបំណងដំបូងនានា គឺផ្ដល់ឱ្យក្រសួងអប់រំ យុវជន និងកីឡា នូវគំរូមួយសម្រាប់ផ្ដល់ការអប់រំពាក់ព័ន្ធ ដែលនឹងបំពេញទៅតាមសេចក្ដីត្រូវការរបស់សហគមន៍ជនជាតិដើមភាគតិច។ មានការគ្រោងទុកថា ចុងក្រោយក្រសួងអប់រំ យុវជន និងកីឡា មិនត្រឹមតែទទួលយកសាលារៀន ដែលបានអនុវត្តការអប់រំពហុភាសាសាកល្បងដំបូងគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងចាប់ផ្ដើមពង្រីកសេវាអប់រំពហុភាសានេះ ទៅកាន់សហគមន៍កាន់តែច្រើនបន្ថែមទៀត ដើម្បីឱ្យសហគមន៍ទាំងនេះអាចទទួលបានសេវាអប់រំពាក់ព័ន្ធ។ UNICEF ក៏ជាដៃគូមួយ នៅក្នុងគម្រោងសាកល្បងនេះផងដែរ និងបានជួយបំពេញថវិកាដែលនៅខ្វះចន្លោះ។

ជោគជ័យដំបូងនៃគម្រោងសាកល្បង HCEP នេះ បាននាំឱ្យមានការបង្កើនការយកចិត្តទុកដាក់ពីនាយកដ្ឋានជាច្រើន នៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសការិយាល័យអប់រំពិសេសក្នុង នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ដែលកាលពីពេលនោះជានាយកដ្ឋានស្រាវជ្រាវគរុកោសល្យ។ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យបានអនុម័តគ្រប់សម្ភារៈកម្មវិធីសិក្សាទាំងអស់ ដែលសរសេរជាភាសាជនជាតិដើមភាគតិច និងភាសាខ្មែរ។ ត្រឹមឆ្នាំ ២០០៧ ជាមួយនឹងការគាំទ្រពី UNICEF ក្រសួងអប់រំ យុវជន និងកីឡា បាន

ចាប់ផ្ដើមដំណើរការពង្រីកគំរូអប់រំពហុភាសាទៅតាមសាលាសហគមន៍ ដែលដំបូងឡើយធ្វើតែនៅក្នុងខេត្តរតនគិរីប៉ុណ្ណោះ។ អង្គការCARE ផ្ដល់ការគាំទ្របច្ចេកទេសដល់ដំណើការនេះ ឯ UNICEF វិញ ផ្ដល់ថវិកាបន្ថែមទៀត។ ក្រោយមក ការពង្រីកការអប់រំពហុភាសា ក៏បានអនុវត្តដោយមន្ទីរអប់រំខេត្តមណ្ឌលគិរី បន្ទាប់មកខេត្តស្ទឹងត្រែង និងក្រោយគេគឺខេត្តក្រចេះ។ គិតត្រឹមឆ្នាំ ២០១៤ ចំនួនសាលាដែលផ្ដល់ការអប់រំពហុភាសា មានការកើនឡើងពី ៦ សាលារៀនក្នុងខេត្តរតនគិរី នៅឆ្នាំ ២០០៣ ក្នុងគម្រោងសាកល្បងដំបូងរបស់ CARE ដល់ ៥៣ សាលារៀន នៅក្នុងខេត្តចំនួន ៤។

នៅក្នុងឆ្នាំ ២០០៩ អង្គការឃែរ CARE កម្ពុជា បានចាប់ផ្ដើមអនុវត្តគម្រោងអប់រំពហុភាសាសាកល្បងមួយទៀត។ គម្រោងសាកល្បងនេះបានអនុវត្តការអប់រំពហុភាសានៅតាមសាលាមត្តេយ្យ។ នាយកដ្ឋានអប់រំកុមារតូចរបស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់អារម្មណ៍ភ្លាមចំពោះគម្រោងនេះ ហើយនៅក្នុងឆ្នាំ ២០១១ នាយកដ្ឋានអប់រំកុមារតូចបានចាប់ផ្ដើមអនុវត្តគម្រោងសាកល្បងរបស់ខ្លួន ដោយបញ្ចូលការអប់រំពហុភាសានៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ចំនួន ២០ កន្លែង នៅក្នុងខេត្តចំនួន ៥ រាប់បញ្ចូលទាំងខេត្តព្រះវិហារផងដែរ។ ការពង្រីកដែលធ្វើឡើងដោយក្រសួងអប់រំ យុវជន និងកីឡា នេះ បានទទួលការគាំទ្រម្ដងទៀតពី UNICEF ជាមួយនឹងការគាំទ្របច្ចេកទេសពី CARE។

នៅក្នុងឆ្នាំ ២០១១ កម្មវិធីអប់រំពហុភាសា នៅក្នុងប្រទេសកម្ពុជា ត្រូវបានវាយតម្លៃដោយបណ្ឌិត Carol Benson មកពីសកលវិទ្យាល័យ Stockholm University[7]។ របាយការណ៍ និងអនុសាសន៍ដែលបានពីការវាយតម្លៃនេះ បានផ្ដល់ឱ្យក្រសួងអប់រំ យុវជន និងកីឡា នូវក្របខ័ណ្ឌដ៏មានប្រយោជន៍មួយ សម្រាប់ធ្វើការអភិវឌ្ឍនាពេលអនាគត និងបន្តធ្វើការកែលំអបន្ថែមទៀត។

អ្វីដែលសំខាន់នោះគឺ បច្ចុប្បន្ននេះ ការអប់រំពហុភាសា ត្រូវបានដាក់បញ្ចូលប្រកបដោយជោគជ័យទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល និងផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡា។ គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសាលាកុមារមេត្រី (អនុក្រុមអប់រំបញ្ចូលគ្នា) ជាអ្នកទទួលខុសត្រូវលើការបន្តអនុវត្តការងារអប់រំពហុភាសានេះ។

[7]បច្ចុប្បន្ននេះ បណ្ឌិត Carol Benson ធ្វើការងារនៅ Teachers College សកលវិទ្យាល័យ Columbia University ទីក្រុងញូយ៉ក។

ឧបសម្ព័ន្ធទី ២ ៖ ក្របខ័ណ្ឌពេលវេលានៃព្រឹត្តិការណ៍សំខាន់ៗ ពាក់ព័ន្ធនឹងការអប់រំពហុភាសា នៅក្នុងប្រទេសកម្ពុជា

១៩៩៥ - ២០០២ ៖ ការអភិវឌ្ឍប្រព័ន្ធអក្ខរក្រម សម្រាប់ភាសាជនជាតិដើមភាគតិចចំនួន ៥ ដោយប្រើប្រាស់អក្សរខ្មែរ ដោយអង្គការ ICC សហការជាមួយនឹងរាជបណ្ឌិតសភាកម្ពុជា។

១៩៩៦ ៖ កម្មវិធីអប់រំពហុភាសាបានចាប់ផ្តើមអនុវត្តនៅក្នុងការអប់រំក្រៅប្រព័ន្ធ សម្រាប់មនុស្សពេញវ័យ អនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ គឺ ICC និង NTFP។

២០០៣ ៖ ក្រសួងអប់រំ យុវជន និងកីឡា អនុម័តប្រព័ន្ធអក្ខរក្រមសម្រាប់ភាសាជនជាតិដើមភាគតិចចំនួន ៥ រួមមាន គ្រឹង ទំពួន ព្នង កាវ៉ែត ព្រៅ។

២០០៣ ៖ កម្មវិធីអប់រំពហុភាសាសាកល្បង បានចាប់ផ្តើមអនុវត្តនៅក្នុងការអប់រំក្នុងប្រព័ន្ធកម្រិត បឋមសិក្សានៅក្នុងភូមិជនជាតិទំពួន និងគ្រឹង ចំនួន ៦ភូមិ នៅក្នុងខេត្តរតនគិរី អនុវត្តដោយអង្គការ CARE ដោយមានការគាំទ្រពី AusAID និង UNICEF។

២០០៧ ៖ ក្រសួងអប់រំ យុវជន និងកីឡា ចាប់ផ្តើមអនុវត្តការអប់រំពហុភាសានៅក្នុងខេត្តរតនគិរី និងមណ្ឌលគិរី បន្ទាប់មកអនុវត្តនៅខេត្តស្ទឹងត្រែងទៀតនៅក្នុងឆ្នាំ ២០០៨ (ដោយមានការគាំទ្រពី UNICEF និងការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីអង្គការ CARE)។

២០០៩ ៖ អង្គការCAREចាប់ផ្តើមអនុវត្តកម្មវិធីអប់រំពហុភាសាសាកល្បងនៅតាមសាលាមត្តេយ្យសិក្សាសហគមន៍នៅក្នុងខេត្តរតនគិរី។

២០១០ ៖ រដ្ឋមន្ត្រីក្រសួងអប់រំ បានចុះហត្ថលេខាលើ "គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំពីរភាសា សម្រាប់កុមារជនជាតិដើមភាគតិច នៅខេត្តនៃតំបន់ខ្ពង់រាប"។

២០១១ ៖ ការវាយតម្លៃខាងក្រៅលើការអនុវត្តការអប់រំពហុភាសា ដោយក្រសួងអប់រំ យុវជន និង កីឡា។

២០១១ ៖ នាយកដ្ឋានអប់រំកុមារតូចបានចាប់ផ្តើមអនុវត្តគម្រោងអប់រំពហុភាសាសាកល្បងនៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ចំនួន ២០ នៅក្នុងខេត្តចំនួន ៥ ដោយមានការគាំទ្រពី UNICEF និងអង្គការ CARE។

២០១៣ ៖ រដ្ឋមន្ត្រីក្រសួងអប់រំចុះហត្ថលេខាលើប្រកាសស្តីពីការកំណត់ភាសាសម្រាប់អ្នកសិក្សាសញ្ជាតិខ្មែរដែលមានដើមកំណើតជាខ្មែរជនជាតិភាគតិច។

២០១៤ ៖ ការរៀបចំបង្កើតផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៥-២០១៨។

ឧបសម្ព័ន្ធទី ៣ ៖ តួនាទីរបស់អង្គការ និងស្ថាប័ននានា នៅក្នុងការអភិវឌ្ឍការអប់រំពហុភាសា នៅ ក្នុងប្រទេសកម្ពុជា

អង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជា (ICC)

ចាប់ពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ មក អង្គការ ICC បានធ្វើការងារ នៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដែលជាខេត្តដាច់ស្រយាលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា។ ដំបូងឡើយ បុគ្គលិករបស់អង្គការ ICC បានសហការជាមួយបុគ្គលិកមកពីវិទ្យាស្ថានភាសាសាំមើ Summer Institute of Linguistics - SIL) និងរាជបណ្ឌិតសភាកម្ពុជា ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីភាសាជនជាតិដើមភាគតិចចំនួន ៥ នៅខេត្តនៃភាគឦសានប្រទេសកម្ពុជា រួចមកបានរៀបចំបង្កើតប្រព័ន្ធអក្ខរកម្មសម្រាប់ភាសាទាំងនេះ។ ក្នុងពេលជាមួយគ្នា អង្គការ ICC បានបង្កើត និងអនុវត្តកម្មវិធីអក្ខរកម្មពហុភាសាសម្រាប់ការអប់រំក្រៅប្រព័ន្ធផងដែរ។ កម្មវិធីអប់រំក្រៅប្រព័ន្ធនេះផ្តោតសំខាន់លើមនុស្សពេញវ័យ។

អង្គការអនុផលព្រៃឈើ (NTFP)

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ មក អង្គការ NTFP បានសហការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការ ICC ដើម្បីរៀបចំនូវកម្មវិធីអក្ខរកម្មក្រៅប្រព័ន្ធ ដោយផ្តោតគោលដៅលើមនុស្សពេញវ័យ។ កម្មវិធីរបស់អង្គការ NTFP មានដាក់បញ្ចូលមុខវិជ្ជាគណិតវិទ្យាមូលដ្ឋាននៅក្នុងកម្មវិធីសិក្សារបស់ខ្លួនផងដែរ។

អង្គការ CARE

អង្គការ CARE បានដើរតួនាទីដឹកនាំក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសានៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ និងបានបន្តផ្តល់ជំនួយបច្ចេកទេសជូនដល់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៃក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិនានា។ ដំណើរការអនុវត្តកម្មវិធី និងការផ្តល់ជំនួយ បច្ចេកទេសអាចប្រព្រឹត្តទៅបាន ដោយអាស្រ័យលើជំនួយឥតសំណងរបស់រដ្ឋាភិបាលអូស្ត្រាលី។ នៅក្នុងឆ្នាំ ២០០២ អង្គការ CARE ដោយសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមធ្វើការងារនៅក្នុងខេត្តរតនគិរី ដើម្បីបង្កើតគំរូអប់រំពហុភាសាក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ។ គម្រោងដំបូង អនុវត្តនៅក្នុងសហគមន៍ដែលមិនធ្លាប់មានសាលារៀនពីមុនមក ដោយដំបូងបំផុត ផ្តោតលើការអប់រំក្មេងស្រី។ សហគមន៍ត្រូវសាងសង់សាលារៀនដោយខ្លួនឯង ដោយអង្គការ CARE បានផ្តល់ការបណ្តុះបណ្តាលគ្រូមកពីតាមសហគមន៍ និងរៀបចំឯកសារសម្ភារៈកម្មវិធីសិក្សាជាភាសាជនជាតិដើមភាគតិច និងភាសាខ្មែរ។ អង្គការ CARE បានបង្កើតនូវគំរូសម្រាប់អនុវត្តការអប់រំពហុភាសាដោយដាក់បញ្ចូលភាសាជនជាតិដើមភាគតិច នៅក្នុងរយៈពេល ៣ ឆ្នាំដំបូងនៃការសិក្សា ដែលគំរូនេះគឺជាមូលដ្ឋានសម្រាប់រៀបចំប្រកាសស្តីពីការអប់រំពហុភាសា នៅក្នុងឆ្នាំ ២០១៣។ ចាប់ពីពេលដែលគម្រោងនេះចាប់ផ្តើម

អង្គការ CARE បានសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (តាំងពីមុនពេលដែលនាយកដ្ឋាននេះត្រូវបានប្តូរឈ្មោះ) និងនាយកដ្ឋានបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ UNICEF បានគាំទ្រដល់ការងាររបស់ CARE ដោយបំពេញថវិកា និងរៀបចំឱ្យការអប់រំពហុភាសាមានរចនាសម្ព័ន្ធផ្លូវការ ក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងឆ្នាំ ២០០៩ អង្គការ CARE បានចាប់ផ្តើមគម្រោងសាកល្បង ដើម្បីអនុវត្តការអប់រំពហុភាសានៅតាមសាលាមត្តេយ្យសហគមន៍។ អង្គការ CARE បាននិងកំពុងកសាងសមត្ថភាពមន្ត្រី សំខាន់ៗនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តការអប់រំពហុភាសា ទាំងនៅកម្រិតមត្តេយ្យសិក្សាទាំងនៅកម្រិតបឋមសិក្សា។ អស់រយៈពេលជាងមួយទសវត្សរ៍មកហើយដែលកម្មវិធីនេះមានការវិវត្តទៅមុខ ហើយកម្មវិធីនេះអាចដំណើរការទៅបានដោយអាស្រ័យមានការទ្រទ្រង់មូលនិធិពីរដ្ឋាភិបាល អូស្ត្រាលី និងម្ចាស់ជំនួយឯកជននៃប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក។

### នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា

ចាប់ពីឆ្នាំ ២០០៤មក ការិយាល័យអប់រំពិសេសនៃនាយកដ្ឋានបឋមសិក្សា បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយអង្គការ CARE ក្នុងការចុះពិនិត្យតាមដាន និងវាយតម្លៃ ដល់ទីតាំងអនុវត្តគម្រោង។ នៅក្នុងឆ្នាំ ២០០៧ នាយកដ្ឋានបឋមសិក្សា តាមរយៈមន្ទីរអប់រំ បានចាប់ផ្តើមអនុវត្តការអប់រំពហុភាសា នៅតាមសាលាសហគមន៍ និងក្រោយមកនៅតាមសាលារដ្ឋ។ ការពង្រីកការអប់រំពហុភាសានេះ ដំបូងឡើយ ធ្វើឡើងតែនៅក្នុងខេត្តរតនគិរីប៉ុណ្ណោះ ហើយក្រោយមកក៏ពង្រីកទៅដល់ខេត្តមណ្ឌលគិរី ស្ទឹងត្រែង និង ក្រចេះ។ មន្ទីរអប់រំខេត្តព្រះវិហារ នៅកំពុងរៀបចំកម្មវិធីអប់រំពហុភាសានេះនៅឡើយ និងមិនទាន់អាចអនុវត្តកម្មវិធីនេះបាននៅឡើយនោះទេ ដោយសារតែមិនទាន់មានការអនុម័តជាផ្លូវការលើប្រព័ន្ធអក្សរក្រមភាសាកួយ។ ការពង្រីកការអប់រំពហុភាសា ដោយនាយកដ្ឋានបឋមសិក្សា ទទួលបានការគាំទ្រពី UNICEF ជាមួយនឹងការឧបត្ថម្ភផ្នែកបច្ចេកទេស និងថវិកាពីអង្គការ CARE។

### នាយកដ្ឋានអប់រំកុមារតូច នៃក្រសួងអប់រំ យុវជន និងកីឡា

នៅក្នុងឆ្នាំ ២០១១ នាយកដ្ឋានអប់រំកុមារតូចបានចាប់ផ្តើមគម្រោងសាកល្បងមួយដែលអនុវត្តការអប់រំពហុភាសា នៅតាមសាលាមត្តេយ្យសហគមន៍ចំនួន ២០ នៅក្នុងខេត្តចំនួន ៥ ជាអាទិ៍ ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងព្រះវិហារ។ ការសាកល្បងនេះ ទទួលបានការគាំទ្រពី UNICEF ជាមួយនឹងការឧបត្ថម្ភផ្នែកបច្ចេកទេសពីអង្គការ CARE។

### UNICEF

UNICEF បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍការអប់រំពហុភាសានៅក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីពេលចាប់ផ្តើមកម្មវិធីមក UNICEF បានគាំទ្រអង្គការ CARE តាមរយៈការបំពេញបន្ថែមនូវថវិកាសម្រាប់ការ

អនុវត្តការអប់រំពហុភាសា បន្ទាប់មកបានផ្តល់ការដឹកនាំ និងថវិកាដ៏ច្រើនដល់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអនុវត្តការអប់រំពហុភាសា។ បន្ទាប់មក UNICEFបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍគោលការណ៍ណែនាំ ស្តីពីការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិចនៅក្នុងខេត្តនៃតំបន់ខ្ពង់រាប ដែលក្រោយមកទទួលបានការអនុម័តពីរដ្ឋមន្ត្រីក្រសួងអប់រំ។ UNICEF នៅតែជាកម្លាំងចលករមួយនៅក្នុងការបន្តការអភិវឌ្ឍការអប់រំពហុភាសា នៅក្នុងប្រទេសកម្ពុជា។

**UNESCO**

ការិយាល័យ UNESCO ប្រចាំអាស៊ីប៉ាស៊ីហ្វិច នៅទីក្រុងបាងកកបានដើរតួនាទីយ៉ាងសកម្មនៅក្នុងការរៀបចំ និងបោះពុម្ពផ្សាយធនធានជាច្រើន ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តការអប់រំពហុភាសា។ ធនធានភាគច្រើន ក្នុងចំណោមធនធានទាំងនេះ ផ្តោតសំខាន់លើតំបន់អាស៊ីអាគ្នេយ៍។ ការិយាល័យនេះក៏មានក្រុមការងារអប់រំពហុភាសាសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិចធ្វើការនៅទីនោះផងដែរ។ ក្រុមការងារនេះគឺជាក្រុមតស៊ូមតិមួយ ដែលមានតួនាទីរៀបចំសន្និសីទអប់រំពហុភាសាពីរដងក្នុងមួយឆ្នាំ និងរៀបចំយុទ្ធសាស្ត្រសម្រាប់បន្តលើកកម្ពស់ការអប់រំពហុភាសានៅក្នុងតំបន់។

ការិយាល័យ UNESCO ប្រចាំទីក្រុងភ្នំពេញ ដើរតួនាទីយ៉ាងសកម្ម នៅក្នុងការគាំទ្រដល់ការអប់រំពហុភាសាក្នុងក្រៅប្រព័ន្ធរបស់ប្រទេសនេះ។ ការិយាល័យនេះធ្វើការងារយ៉ាងជិតស្និទជាមួយនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា។

## ឧបសម្ព័ន្ធទី ៤ ៖ គំរូអប់រំពហុភាសាដែលអនុវត្តនៅក្នុងការអប់រំក្នុងប្រព័ន្ធនៅកម្ពុជា

<table>
<tr><td colspan="3">កម្រិតបឋមសិក្សា</td></tr>
<tr><td colspan="3">ថ្នាក់ទី ៦<br>ភាសាខ្មែរ ១០០%</td></tr>
<tr><td colspan="3">ថ្នាក់ទី ៥<br>ភាសាខ្មែរ ១០០%</td></tr>
<tr><td colspan="3">ថ្នាក់ទី ៤<br>ភាសាខ្មែរ ១០០%</td></tr>
<tr><td>ថ្នាក់ទី ៣<br>ភាសាកំណើត ៣០%<br>សិក្សាភាសាកំណើត ១៥%<br>សិក្សាសង្គម ១៥%</td><td colspan="2">ភាសាខ្មែរ ៧០%<br>គណិតវិទ្យា ១៥%<br>សិក្សាភាសាខ្មែរ ៤៥%<br>សិក្សាសង្គម ១០%</td></tr>
<tr><td colspan="2">ថ្នាក់ទី ២<br>ភាសាកំណើត ៦០%<br>សិក្សាភាសាកំណើត ២៥%<br>សិក្សាសង្គម ៣៥%</td><td>ភាសាខ្មែរ ៤០%<br>សិក្សាភាសាខ្មែរ ២៥%<br>គណិតវិទ្យា ១៥%</td></tr>
<tr><td colspan="2">ថ្នាក់ទី ១<br>ភាសាណើត ៨០%<br>គណិតវិទ្យា ១៥%<br>សិក្សាសង្គម ៣៥%<br>សិក្សាភាសាកំណើត ៣០%</td><td>ភាសាខ្មែរ ២០% (សម្រាប់តែការនិយាយប៉ុណ្ណោះ)</td></tr>
<tr><td colspan="3">កម្រិតមត្តេយ្យសិក្សា</td></tr>
<tr><td></td><td>កុមារអាយុ ៣ និង ៤ ឆ្នាំ</td><td>កុមារអាយុ ៥ ឆ្នាំ</td></tr>
<tr><td>ឆមាសទី ១</td><td>តែភាសាកំណើតប៉ុណ្ណោះ</td><td>តែភាសាកំណើតប៉ុណ្ណោះ</td></tr>
<tr><td>ឆមាសទី ២</td><td>តែភាសាកំណើតប៉ុណ្ណោះ</td><td>ភាសាកំណើត ឬកនឹងភាសាខ្មែរ ២០ នាទី ជារៀងរាល់ថ្ងៃ (ភាសាខ្មែរសម្រាប់តែការនិយាយប៉ុណ្ណោះ)</td></tr>
</table>

## ឧបសម្ព័ន្ធទី ៥ ៖ សន្ទរកថាស្តីពីការអប់រំពហុភាសារបស់លោកជំទាវ ទន់ សាអុឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

បើតាមការអង្កេតចន្លោះជំរឿនប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០១៣ ព្រះរាជាណាចក្រកម្ពុជាមានប្រជាជនចំនួន ១៤,៨៦ លាននាក់។ ធនាគារពិភពលោក (២០១២) កំណត់ថា ប្រជាជន ៥% គឺជាជនជាតិភាគតិច។ ជនជាតិទាំងនេះរួមមាន ចិន វៀតណាម ចាម ឡាវ ព្រៅ ថាវាយ កាចក់ ខោញ ក្លឹង្គ ក្រោល កាវ៉ែត គ្រឹង កួយ សើយ ល្អឺន មិល ព័រ ព្នង[8] រដែ រអង សំរែ ស្ទូច ស្មៀង ប៊ូឡូ សួយ ទំពួន និងថ្មូន។ ក្រុមមួយចំនួនបាននិងកំពុងរស់នៅតាមសហគមន៍ ជាមួយនឹងពលរដ្ឋខ្មែរ ហើយមួយចំនួនទៀតកំពុងរស់នៅតាមសហគមន៍របស់ពួកគេ ជាពិសេស នៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ ឧត្តរមានជ័យ កំពង់ចាម ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងតំបន់ដទៃទៀតនៅក្នុងប្រទេស។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងនៅក្នុងមាត្រា ៣១ ថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ច ដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ មាត្រា ៥២ បង្ហាញពីការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងផ្តល់នូវកិច្ចការពារស្របច្បាប់ដល់ប្រជាពលរដ្ឋទាំងអស់របស់ប្រទេសនេះ ដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងអស់ ដោយពុំមានការរើសអើងអ្វីទាំងអស់។ មាត្រា ៦៧ លើកឡើងពីការគ្រប់គ្រង និងអភិវឌ្ឍន៍កម្មវិធីសិក្សា ស្របទៅតាមគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។ មាត្រា ៦៨ លើកឡើងពីការផ្តល់ការអប់រំកម្រិតមូលដ្ឋាន ដោយឥតបង់ថ្លៃ នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់អាចចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានអប់រំសាធារណៈ និងទទួលបានការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ។ មាត្រា ៦៩ លើកឡើងពីការអភិរក្ស និងការអភិវឌ្ឍបេតិកភ័ណ្ឌវប្បធម៌ជាតិ។

រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតគណៈកម្មាធិការជាតិមួយ ដើម្បីគ្រប់គ្រងដំណើរការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ហើយខ្ញុំគឺជាសមាជិកមួយរូបរបស់គណៈកម្មាធិការនេះ ក្នុងនាមតំណាងឱ្យក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡា មានក្តីបារម្ភជាយូរមកហើយ ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការអប់រំរបស់ក្រុមជនជាតិដើមភាគតិច។ ក្តីបារម្ភនេះបាននាំឱ្យមានការពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា។ លទ្ធផលនៃការពិភាក្សាទាំងនេះ គឺការបង្កើតគម្រោងសាកល្បងមួយ ដើម្បីអនុវត្តការអប់រំពីរភាសានៅកម្រិតបឋមសិក្សា សម្រាប់ក្រុមជនជាតិដើមភាគតិចចំនួន ២ គឺជនជាតិ ទំពួន និងគ្រឹង នៅក្នុងខេត្តរតនគិរី។ គម្រោងសាកល្បងនេះ នៅស្ថិត

[8] ភាសាអង់គ្លេសអាចសរសេរ Phnorng ឬ Bunong

ក្រោមការពិនិត្យ និងតាមដានរបស់គណៈកម្មាធិការ និងការិយាល័យអប់រំពិសេសនៃនាយកដ្ឋានបឋមសិក្សា ហើយក្រោយមក គម្រោងនេះបានក្លាយគម្រោងផ្លូវការ តាមរយៈប្រកាសលេខ ៤៨ ឆ្នាំ ២០១៣។

បន្ថែមពីលើការងារខាងលើនេះ រាជរដ្ឋាភិបាលបានរៀបចំច្បាប់ថ្មីមួយស្តីពីការផ្តល់សេវាអប់រំ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ដោយព្រះរាជក្រម នៅក្នុងឆ្នាំ ២០០៧។ ច្បាប់ថ្មីនេះចែងថា សេវាអប់រំប្រកបដោយគុណភាពត្រូវតែផ្តល់ដោយសមធម៌ និងដោយមិនគិតថ្លៃ ចាប់ពីការអប់រំកុមារតូច រហូតដល់ការអប់រំមធ្យមសិក្សាចំណេះទូទៅ។ មាត្រា២៤នៃច្បាប់នេះចែងថា ភាសាខ្មែរគួរជាភាសាបង្រៀននិងរៀន សម្រាប់កម្មវិធីសិក្សាជាតិ ហើយភាសាដែលត្រូវប្រើសម្រាប់ការអប់រំជនជាតិដើមភាគតិច ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យនេះ។ លើសពីនេះ រដ្ឋាភិបាលក៏បានរៀបចំនូវ គោលនយោបាយជាតិមួយស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្ត នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩។ គោលនយោបាយនេះផ្តល់អាទិភាពដល់សិស្សមកពីតំន់ភូមិភាគឦសាន្តដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឱ្យចូលរៀននៅតាមសកលវិទ្យាល័យនានានៅរាជធានីភ្នំពេញ។ ដើម្បីកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវទិសដៅខាងក្រោម សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ៖

- កសាង និងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និងក្រមសីលធម៌ខ្ពស់បំផុត នៅក្នុងគ្រប់វិស័យទាំងអស់ ដើម្បីឆ្លើយតបទៅនឹងអាទិភាពតម្រូវការសង្គម ផលប្រយោជន៍ និងបំណងប្រាថ្នារបស់ជនជាតិដើមភាគតិចខ្លួនឯង។

- រដ្ឋត្រូវបង្កើតនូវប្រព័ន្ធអប់រំទូលំទូលាយមួយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ ជនជាតិដើមភាគតិច និងត្រូវផ្តល់ឱកាសអប់រំសមស្របដល់កុមារ យុវជន និងយុវតីមកពីសហគមន៍ជនជាតិដើមភាគតិច។ រដ្ឋត្រូវពិចារណាលើការរៀនសូត្ររបស់ជនជាតិដើមភាគតិច តាមរយៈការផ្តល់នូវសម្ភាររូបវ័ន្ត និងកែទម្រង់កម្មវិធីសិក្សា ដែលមានប្រយោជន៍ដល់សង្គម។ ដើម្បីឱ្យសិស្សជនជាតិដើមភាគតិចអាចបន្តការអប់រំរបស់ខ្លួនដល់កម្រិតមធ្យមសិក្សា ការអប់រំបច្ចេកទេស និងការអប់រំថ្នាក់ឧត្តមសិក្សា ត្រូវមានការផ្តល់អន្តេវាសិកដ្ឋាន អាហារូបករណ៍ និងការផ្តល់ប្រាក់ឧបត្ថម្ភ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពង្រាយគ្រូទៅកាន់តំបន់ជនជាតិដើមភាគតិច។

- ការអប់រំក្រៅប្រព័ន្ធ សម្រាប់ជនជាតិដើមភាគតិច នឹងត្រូវរៀបចំឡើង ដើម្បីដាក់បញ្ចូលអក្ខរកម្ម ចំណេះដឹងអំពីលេខ ជំនាញការងារ បំណិនជីវិត និងការអប់រំកម្រិតមូលដ្ឋាន ក្នុងគោលបំណងផ្តល់ឱ្យពួកគេនូវជំនាញសិក្សាធិការជាមូលដ្ឋានឱ្យបានល្អប្រសើរ ក៏ដូចជាចំណេះដឹងអំពីវប្បធម៌ និងសាសនា។ នេះនឹងផ្តល់លទ្ធភាពឱ្យយុវជនក្រៅសាលា មានចំណេះដឹងអក្ខរកម្មវិជ្ជាជីវៈ និង អភិវឌ្ឍសមត្ថភាពរបស់ពួកគេ សម្រាប់ការធ្វើការងារ ការគ្រប់គ្រងជីវិត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឯកសារអក្ខរកម្មដល់ថ្នាក់ទី ៤ ជាភាសាខ្មែរ និង

ភាសាជនជាតិដើមភាគតិច ត្រូវបានរៀបរៀងឡើង សម្រាប់យុវជនទាំងនេះ។ ឯកសារទាំងនេះបានផ្តល់នូវជំនួយយ៉ាងធំធេងដល់ការចុះឈ្មោះយុវជនក្នុងកម្មវិធីអប់រំនានា។

- បេក្ខជនជាជនជាតិដើមភាគតិច នឹងទទួលបានអាទិភាព សម្រាប់ការជ្រើសរើសឱ្យចូលក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ។ នេះនឹងនាំឱ្យមានគ្រូ ដែលមានសមត្ថភាពប្រើប្រាស់ភាសាចំនួនពីរ នៅក្នុងថ្នាក់រៀន ពោលគឺភាសាខ្មែរផង និងភាសាជនជាតិផង។ ការលើកទឹកចិត្តជាច្រើន ដូចជាប្រាក់រង្វាន់សម្រាប់ប៉ុស្តិ៍ការងារ និងប្រាក់ឧបត្ថម្ភបន្ថែមទៀតនឹងត្រូវរៀបចំឡើងដើម្បីលើកទឹកចិត្តឱ្យសិស្សបញ្ចប់ការសិក្សាពីសាលាគរុកោសល្យទៅធ្វើការងារតាមសហគមន៍ជនជាតិដើមភាគតិច នៅតំបន់ដាច់ស្រយាល។

- មជ្ឈមណ្ឌលសហគមន៍ នឹងត្រូវបានបង្កើតឡើង នៅតាមតំបន់ភាគឦសាន ដែលមានជនជាតិដើមភាគតិចរស់នៅ ដើម្បីអភិវឌ្ឍឯកសារ និងសម្ភារៀន ដែលសមស្របសម្រាប់ការបង្រៀននិងរៀន នៅក្នុងថ្នាក់រៀនពហុភាសា។

ដោយប្រើប្រាស់ក្របខ័ណ្ឌគតិយុត្តិ ដូចរៀបរាប់ខាងលើ និងជាមួយនឹងបទពិសោធន៍ ដែលទទួលបានពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ ក្នុងចំណោមដៃគូអភិវឌ្ឍន៍នានា ក្រសួងអប់រំ យុវជន និងកីឡា សម្រេចបង្កើតគណៈកម្មាធិការអប់រំពហុភាសាមួយ ដើម្បីរៀបចំគោលការណ៍ណែនាំផ្លូវការលេខ ២៩៧២ អយក.បស ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១០ ស្តីពីការអនុវត្តការអប់រំពហុភាសា។ គណៈកម្មាធិការនេះក៏បានសហការផងដែរជាមួយនឹងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសៀវភៅសិក្សាពី ថ្នាក់ទី ១ ដល់ថ្នាក់ទី ៣ សម្រាប់ការអប់រំពហុភាសានៅបឋមសិក្សា។ លើសពីនេះ វចនានុក្រមពហុភាសាកម្រិតដំបូង និងឯកសារកម្មវិធីសិក្សាផ្សេងទៀត ក៏ត្រូវបានរៀបចំឡើងផងដែរ។ កម្មវិធីពហុភាសានេះ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឱ្យកុមារជនជាតិដើមភាគតិចនូវស្ពាន សម្រាប់ឆ្លងទៅប្រើប្រាស់ភាសាជាតិ។ គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីពហុភាសា ចែងពីការប្រើប្រាស់ភាសា នៅក្នុងភូមិសិក្សាបឋមសិក្សាទាំងមូល។ ថ្នាក់ទី ១ ត្រូវប្រើភាសាកំណើតរបស់ជនជាតិដើមភាគតិច ៨០% និងត្រូវប្រើភាសាខ្មែរ ២០%។ ថ្នាក់ទី ២ ត្រូវភាសាកំណើតរបស់ជនជាតិដើមភាគតិច ៦០% និងត្រូវប្រើភាសាខ្មែរ៤០%។ ថ្នាក់ទី ៣ ត្រូវប្រើភាសាកំណើតរបស់ជនជាតិដើមភាគតិច ៣០% និងត្រូវប្រើភាសាខ្មែរ ៧០%។ ចាប់ពីថ្នាក់ទី ៤ ដល់ទី ៦ ត្រូវប្រើភាសាខ្មែរ ១០០%។

គិតមកទល់នឹងពេលបច្ចុប្បន្ននេះ[9] នៅក្នុងខេត្តចំនួន៤ នៅភូមិភាគឦសាន ពោលគឺខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង មានសាលារៀនចំនួន ៥៣ ដែលកំពុងផ្តល់សេវាអប់រំពហុភាសាដល់កុមារមកពីក្រុមជនជាតិដើមភាគតិច។ មានគ្រូអប់រំពហុភាសា ១២៧នាក់ ស្រី ៤៤ នាក់ ហើយពួកគេសុទ្ធតែជាអ្នកមកពីក្រុមជនជាតិដើមភាគតិច។ មានកុមារជនជាតិដើមភាគតិចចំនួន ៤០៤៤ នាក់ (ស្រី ១៩៦៦ នាក់) ចុះឈ្មោះចូលរៀនក្នុងសាលា ដែលផ្តល់ការអប់រំ

[9]បើតាមឆ្នាំសិក្សាថ្មី ២០១៤-២០១៥

ពហុភាសា។ យើងបានផលិតសៀវភៅសិក្សាចំនួន ៧៨ ចំណងជើង ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះ មានយុវជនប្រមាណជា ២០០នាក់ មកពីតាមសាលាពហុភាសាទាំងនេះបានទទួលជោគជ័យក្នុងការប្រឡងកម្រិតមធ្យមសិក្សា និងកំពុងបន្តការអប់រំនៅកម្រិតឧត្តមសិក្សា។ ពួកគេមួយចំនួនបានបញ្ចប់ការសិក្សា និងកំពុងធ្វើការងារ នៅតាមវិស័យផ្សេងៗ ដូចដែលផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ។

បើទោះបីជាមានការសម្រេចនូវសមិទ្ធផលទាំងនេះក៏ដោយ កម្មវិធីនេះក៏ជួបប្រទះនឹងការលំបាកផងដែរ ដែលទាមទារឱ្យមានការចូលរួមឱ្យបានសកម្មពីដៃគូអភិវឌ្ឍន៍ និងការគាំទ្រពីថ្នាក់ដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

បញ្ហាប្រឈមទាំងនេះ រួមមាន ៖

- កម្មវិធីអប់រំពហុភាសានេះអនុវត្តចំពោះភាសាជនជាតិដើមភាគតិចចំនួនតែ ៥ ភាសាប៉ុណ្ណោះ ដូចជាគ្រឹង ទំពួន កាវ៉ែត ព្រៅ និងព្នង។
- លក្ខណៈវិនិច្ឆ័យផ្លូវការ សម្រាប់ជ្រើសរើសគ្រូបឋមសិក្សា បង្កឱ្យមានឧបសគ្គមួយចំនួន ចំពោះគរុសិស្សជនជាតិដើមភាគតិច ដែលមានសក្ដានុពល។
- អត្រាបោះបង់ការសិក្សា នៅការអប់រំកម្រិតមូលដ្ឋាន នៅតែជាបញ្ហាប្រឈម និងមានបញ្ហាប្រឈមទាក់ទងនឹងការផ្ដល់ និងការបន្តគ្រប់គ្រងលើអន្តេវាសិកដ្ឋាន។
- អន្តេវាសិកដ្ឋាន ដើម្បីផ្ដល់កន្លែងស្នាក់នៅ និងការលើកទឹកចិត្តដល់គ្រូ នៅមិនទាន់អាចឆ្លើយតបទៅនឹងសេចក្ដីត្រូវការបាន។

## ឧបសម្ព័ន្ធទី ៦ ៖ ភាពស្ទាត់ជំនាញខាងភាសាចំនួន ២ ប្រភេទ

លោក Jim Cummins ដែលជាអ្នកជំនាញល្បីឈ្មោះខាងការអប់រំភាសាបានបង្កើតទ្រឹស្តីមួយអំពីការរៀនភាសា និងសមត្ថភាពផ្នែកភាសា។ គាត់បានសន្និដ្ឋានថា សមត្ថភាពផ្នែកភាសាមាន ២ ប្រភេទ គឺជំនាញប្រាស្រ័យទាក់ទងអន្តរបុគ្គលជាមូលដ្ឋាន (BICS) ដែលគេហៅម្យ៉ាងទៀតថាភាសាសង្គម និងភាពស្ទាត់ជំនាញខាងភាសាប្រើប្រាស់ក្នុងការរៀនសូត្រ (CALP) ដែលគេហៅម្យ៉ាងទៀតថា ភាសាសម្រាប់ការសិក្សាធិការ។ ទ្រឹស្តីអំពី BICS និង CALP នេះ គឺជាទ្រឹស្តីដែលអាចមានប្រយោជន៍យ៉ាងខ្លាំង នៅក្នុងការពន្យល់ពីស្ថានភាពភាសា នៅតាមសហគមន៍ជនជាតិភាគតិចជាច្រើន ហើយក៏អាចជាហេតុផលដែលនាំឱ្យមានភាពចាំបាច់ត្រូវផ្តល់ការអប់រំពហុភាសា តាមសហគមន៍ទាំងនេះ បើទោះបីជាមានកុមារមួយចំនួនហាក់បីដូចជាចេះនិយាយភាសាខ្មែរ ដែលជាភាសាជាតិយ៉ាងណាក៏ដោយ។

គ្រូប្រចាំថ្នាក់ចាំបាច់ត្រូវយល់ពីភាពខុសប្លែកគ្នារវាងការចេះភាសាសង្គម និងភាសាសម្រាប់ការសិក្សា។ ខាងក្រោមនេះ គឺជាសេចក្តីពិពណ៌នាអំពី BICS និង CALP។

### ជំនាញប្រាស្រ័យទាក់ទងអន្តរបុគ្គលជាមូលដ្ឋាន

អ្នកជំនាញបានធ្វើការបែងចែកភាពខុសប្លែកគ្នារវាងការទទួលបានភាសាសង្គម និងភាសាសម្រាប់ការសិក្សា។ ជំនាញប្រាស្រ័យទាក់ទងអន្តរបុគ្គលជាមូលដ្ឋាន (BICS) សំដៅលើជំនាញភាសាដែលចាំបាច់នៅក្នុងស្ថានភាពសង្គម។ វាគឺជាភាសាប្រចាំថ្ងៃ ដែលចាំបាច់សម្រាប់ការប្រាស្រ័យទាក់ទង ក្នុងសង្គមជាមួយនឹងមនុស្សផ្សេងទៀត។ អ្នករៀនភាសាប្រើប្រាស់ជំនាញ BICS នៅពេលដែលពួកគេលេងនៅសួនកុមារ នៅលើទីធ្លាសាលា និងពិធីជប់លៀង ពេលលេងកីឡានិងនិយាយទូរស័ព្ទជាដើម។ ជាធម្មតា ការប្រាស្រ័យទាក់ទងក្នុងសង្គមមានដាក់បញ្ចូលនូវតម្រុយបរិបទ និងគាំទ្រដោយវត្ថុបី។ ការប្រាស្រ័យទាក់ទងរបៀបនេះកើតឡើង នៅក្នុងបរិបទសង្គមដែលមានអត្ថន័យអាចយល់បាន។ ការប្រាស្រ័យទាក់ទងបែបនេះមានលក្ខណៈងាយស្រួល និងពុំត្រូវការការគិត ឬចំណេះដឹងច្រើនឡើយ។ ភាសាដែលគេត្រូវយកមកប្រើមិនមែនជាភាសាឯកទេសឡើយ។ ជាធម្មតា ជំនាញភាសាទាំងនេះអភិវឌ្ឍក្នុងរយៈពេលពី ៦ខែ ដល់ ២ឆ្នាំ ក្រោយពេលដែលអ្នករៀនសូត្រម្នាក់ ចាប់ផ្តើមរៀនភាសាថ្មីនេះ។

បញ្ហាកើតឡើង នៅពេលដែលគ្រូ និងអ្នកគ្រប់គ្រងសាលារៀន គិតថា កុមារចេះភាសាមួយស្ទាត់ជំនាញ នៅពេលដែលពួកគេបង្ហាញពីភាសាសង្គម (BICS) បានល្អ។

### ភាពស្ទាត់ជំនាញខាងភាសាប្រើប្រាស់ក្នុងការរៀនសូត្រ

CALP សំដៅលើភាសា ដែលចាំបាច់សម្រាប់ការរៀនសូត្រផ្លូវការ។ នេះរួមមានការស្តាប់ ការនិយាយ ការអាន និងការសរសេរអំពីខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទអ្វីមួយ។ ការរៀនសូត្រភាសានៅកម្រិតនេះ មានសារៈសំខាន់ ដើម្បីឱ្យសិស្សអាចទទួលបានជោគជ័យក្នុងសាលារៀន។ សិស្សត្រូវការពេល និងការគាំទ្រ ដើម្បីមានភាពស្ទាត់ជំនាញខាង

ភាសា ដែលប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវ។ ជាធម្មតា គេត្រូវការពេលពី ៥ ដល់ ៧ឆ្នាំ។ ការស្រាវជ្រាវដ៏សំខាន់មួយ (Thomas & Collier, 1995) បានបង្ហាញថា ប្រសិនបើកុមារម្នាក់មិនធ្លាប់ទៅរៀនកន្លងមក ឬមិនបានទទួលការគាំទ្រខាងការអភិវឌ្ឍភាសាកំណើតរបស់ខ្លួននោះទេ វាអាចត្រូវការពេលពី ៧ ដល់ ១០ ឆ្នាំ សម្រាប់សិស្សដើម្បីរៀនឱ្យទាន់គេ។ ជារឿយៗ ពួកគេមិនអាចតាមគេទាន់តែម្តង។

ការរៀនចេះភាសាសម្រាប់ការសិក្សា មិនត្រឹមតែជាការយល់ពីវាក្យសព្ទ ដែលប្រើប្រាស់សម្រាប់ខ្លឹមសារមេរៀននោះទេ វាក៏រាប់បញ្ចូលជំនាញនានាដូចជា ការប្រៀបធៀប ការបែងចែក ការធ្វើចំណែកថ្នាក់ ការសំយោគការវាយតម្លៃ ការវិភាគ និងការកាត់យល់ ជាដើម។ ភាសាសម្រាប់ការសិក្សាពុំមានបង្ហាញតម្រុយបរិបទទេ បើមានក៏មានក្នុងចំនួនតិចតួចដែរ។ ព័ត៌មានត្រូវបានអានពីសៀវភៅសិក្សា ឬត្រូវបានបង្ហាញដោយគ្រូ។ នៅពេលដែលសិស្សកាន់តែមានអាយុច្រើន តម្រុយបរិបទនៃភាសាសម្រាប់ការសិក្សាកាន់តែតិចទៅៗ ហើយភាសាកាន់តែអរូបីទៅៗ។

ភាសា ក៏កាន់តែមានការលំបាកឡើងៗ និងត្រូវការការគិតកាន់តែច្រើន។ គំនិត បញ្ញត្តិ និងភាសាថ្មីៗ ត្រូវបានបង្ហាញទៅកាន់សិស្ស ក្នុងពេលជាមួយគ្នា។

ផលវិបាកសម្រាប់គ្រូ

ជាការសំខាន់ ដែលគ្រូ និងអ្នកអប់រំត្រូវដឹងពី BICS និង CALP។ ប្រសិនបើគ្រូមិនបានពិចារណា អំពីភាពខុសប្លែកគ្នារវាង BICS និង CALP នោះទេ វាអាចនាំឱ្យមានការវាយតម្លៃមិនយុត្តិធម៌ចំពោះសិស្ស។

អ្នកអប់រំត្រូវប្រុងប្រយ័ត្នកុំធ្វើការភ្ជាប់ទំនាក់ទំនងការរៀនខ្សោយ (របស់សិស្ស) ទៅនឹងបញ្ហាខ្សោយ (របស់សិស្ស)។ ជារឿយៗ ការរៀនខ្សោយអាចបណ្តាលមកពីកង្វះចំណេះដឹងពីមុន ឬកង្វះវាក្យសព្ទទាក់ទងនឹងខ្លឹមសារដែលគ្រូកំពុងតែបង្រៀន។ ជាងនេះទៅទៀត អ្នកសិក្សាទាំងនេះត្រូវការពេលវេលាបន្ថែម ដើម្បីយល់ព័ត៌មាននៅក្នុងភាសាមួយដែលថ្មី។

គេអាចរៀន BICS ចេះ បានយ៉ាងលឿន ពីព្រោះនៅក្នុងការសន្ទនាទល់មុខគ្នាប្រចាំថ្ងៃ អត្ថន័យត្រូវបានបញ្ជាក់តាមរយៈទីបញ្ជាក់សេចក្តីនៅក្នុងបរិបទដូចជាស្ថានភាពជាក់ស្តែង កាយវិការ ការលើកដាក់សំឡេង ទឹកមុខ ព័ត៌មានត្រឡប់ភ្លាមៗ ការចរចាអំពីអត្ថន័យ។ល។ ប្រការនេះកម្រកើតមានឡើងនៅក្នុងCALP ណាស់ ព្រោះវាជាភាសាសម្រាប់ការសិក្សា និងភាសាដែលប្រើក្នុងសៀវភៅសិក្សា។

កិច្ចការដែលទាក់ទងនឹងការសិក្សា តម្រូវឱ្យអ្នករៀនស្វែងយល់ភាសាក្នុងអត្ថបទ ដោយពុំមានការបញ្ជាក់អត្ថន័យពីទីបញ្ជាក់សេចក្តីក្នុងបរិបទ ដែលមាននៅក្នុងភាសាសម្រាប់ការសន្ទនា។ ភាសាសម្រាប់ការសិក្សាមានលក្ខណៈផ្លូវការច្រើន អរូបីច្រើន និងវាក្យសព្ទមានលក្ខណៈជាប់ទាក់ទងគ្នាច្រើន ជាពិសេសជាប់ពាក់ព័ន្ធទៅនឹងប្រធានបទ។ ជារួម ភាសាសម្រាប់ការសិក្សាមានភាពខុសគ្នាយ៉ាងធំធេងពីភាសា ដែលយើងប្រើសម្រាប់ការនិយាយនៅក្នុងអន្តរកម្ម

ប្រចាំថ្ងៃ។ ហេតុដូច្នេះហើយ វាមិនត្រឹមតែពិបាកយល់យ៉ាងខ្លាំងប៉ុណ្ណោះទេ ថែមទាំងពិបាកយ៉ាងខ្លាំងសម្រាប់សិស្សជនជាតិដើមភាគតិចនៅក្នុងការប្រើប្រាស់ និងបង្កើតភាសានេះនៅក្នុងកិច្ចការស្រាវជ្រាវជាសំណេរ ឬប្រើប្រាស់នៅក្នុងអំឡុងពេលពិភាក្សាក្នុងថ្នាក់រៀន។

លើសពីនេះ សិស្សជនជាតិដើមភាគតិចព្យាយាមរៀនឱ្យទាន់សិស្សដែលនិយាយភាសាខ្មែរ នៅពេលមួយដែលសិស្សខ្មែរទាំងនេះកំពុងតែមានភាពរីកចម្រើនផ្នែកបំណិននានា ក្នុងភាសាសម្រាប់ការសិក្សា។ ការព្យាយាមរៀនឱ្យទាន់គេនៅក្នុងស្ថានភាពបែបនេះ តម្រូវឱ្យមានការតាំងចិត្ត និងយុទ្ធសាស្ត្រដែលផ្តោតលើការរៀន។ សិស្សមួយចំនួនគិតថា កិច្ចការនេះគឺពិបាកខ្លាំងពេក។ ពួកគេលែងប្រឹងប្រែង និងដកខ្លួនចេញពីការសិក្សា ឬបោះបង់ការសិក្សាទាំងស្រុងតែម្តង។ បើផ្អែកទៅតាមលទ្ធផលរបស់សិស្សទាំងនេះខាងភាសា BICS ពេលខ្លះ សិស្សទាំងនេះត្រូវបានគេគិតថាជាសិស្សខ្ជិល ដោយសារតែគ្រូមិនដឹងថា តាមពិត សិស្សទាំងនេះកំពុងជួបប្រទះការលំបាក ពាក់ព័ន្ធជាមួយនឹងភាសា CALP នោះ។

## ឧបសម្ព័ន្ធទី ៧ ៖ សន្ទានុក្រមនៃវាក្យសព្ទ ដែលច្រើនប្រើនៅក្នុងការអប់រំពហុភាសា

ការផ្ដាច់ខ្លួន (Alienation) ៖ ការដាច់ទំនាក់ទំនងពីភាសា និងវប្បធម៌របស់ខ្លួន។

ការលើកកម្ពស់ការយល់ដឹង (Awareness raising) ៖ ការផ្ដល់ព័ត៌មានដែលអាចជួយមនុស្សឱ្យសម្រេចគោលដៅ និងតម្រូវការដែលពួកគេបានកំណត់សម្រាប់ខ្លួនឯង។

ពីរភាសា (Bilingual)

- កម្រិតបុគ្គល ៖ សមត្ថភាពនិយាយ/យល់ (និងពេលខ្លះ អាន/សរសេរ) យ៉ាងហោចណាស់ ២ ភាសា។
- កម្រិតសង្គម ៖ វត្តមាននៃក្រុមភាសាយ៉ាងហោចណាស់ចំនួន ២។

សមត្ថភាព (Competencies) ៖ ចំណេះដឹង សមត្ថភាព ឬជំនាញខាងភាសា ឬមុខវិជ្ជាដទៃទៀតនៃកម្មវិធីសិក្សា។

កម្មវិធីសិក្សា (Curriculum) ៖ ផែនការ ខ្លឹមសារ និងឯកសារបង្រៀននិងរៀន សម្រាប់កម្មវិធីអប់រំណាមួយ។

ក្រុមធំទូទៅ (Dominant group) ៖ ក្រុមមនុស្សក្នុងសង្គមដែលមានអំណាចបំផុតរបស់ប្រទេស ដោយសារតែចំនួន (ចំនួនភាគច្រើន) សេដ្ឋកិច្ច (ទ្រព្យសម្បត្តិ) និង/ឬនយោបាយ (អំណាច)។

ភាសាដែលគេប្រើទូទៅ (Dominant language) ៖ ភាសាដែលនិយាយដោយក្រុមដែលមានចំនួនភាគច្រើននៅក្នុងសង្គម ឬភាសាដែលត្រូវបានគេចាត់ទុកថាជាភាសាគោលរបស់ប្រទេសមួយ។

ការអប់រំពហុភាសាដោយប្រើប្រាស់ភាសាទី១ (First Language First MLE) ៖ ការបង្រៀននិងរៀនដែលចាប់ផ្ដើមដោយភាសាទី១ (L1) សម្រាប់ការអាន និងសរសេរ ខណៈនោះក៏មានបង្រៀនភាសាទី២ (L2) ផងដែរ។

ភាពស្ទាត់ជំនាញ (Fluency) ៖ សមត្ថភាពខ្ពស់ខាងការនិយាយ និងការអាន ឬការសរសេរភាសាអ្វីមួយ។

ភាសាកេរដំណែល (Heritage language) ៖ ភាសាបុព្វបុរសរបស់មនុស្សម្នាក់ ឬរបស់ក្រុមភាសាជនជាតិភាគតិច។

ភាសាកំណើត (Home language) ៖ ភាសាដែលគេនិយាយតាមផ្ទះ ពេលខ្លះហៅថាភាសាទី១ 'L1' ឬ "ភាសាកំណើត (mother tongue)"។

ការអនុវត្ត (Implementation) ៖ ដំណើរការនៃការកៀរគរមនុស្ស និងធនធាន ដើម្បីអនុវត្តកម្មវិធីថ្មីមួយ។

អន្តរវប្បធម៌ (Interculturalism) ៖ ការលើកកម្ពស់ការយល់ដឹង និងការអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមករវាងក្រុមភាសាជនជាតិភាគតិច និង/ឬក្រុមសង្គមផ្សេងៗគ្នា។

L1: ភាសាទី ១ ភាសាកំណើត (សំដៅលើភាសាមួយ ឬច្រើន ដែលរៀនតាំងពីកំណើត)។

L2: ភាសាទី ២ ភាសាមិនមែនជាភាសាកំណើត ភាសាដែលគេប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទងទូលំទូលាយជាង ឬភាសាបរទេស។

ការអភិវឌ្ឍភាសា (Language Development)

- នៅក្នុងការអប់រំ៖ ការបង្រៀនមនុស្សម្នាក់ឱ្យចេះនិយាយ អាន និងសរសេរភាសាអ្វីមួយឱ្យបានស្ទាត់ជំនាញ។
- នៅក្នុងសហគមន៍និយាយភាសាជនជាតិភាគតិច ៖ ការលើកកម្ពស់នូវការប្រើប្រាស់ភាសាមួយដោយការនិយាយ និងការសរសេរដូចជា តាមរយៈការពង្រីកចំនួនវាក្យសព្ទ ការព្រមព្រៀងគ្នាលើទម្រង់សំណេរ ការបង្កើតសៀវភៅ ឯកសារ និងសម្ភារសិក្សានានា។

ភាសាបង្រៀននិងរៀន (Language of Instruction) ៖ ភាសាដែលគេប្រើសម្រាប់ការបង្រៀន និងរៀនក្នុងកម្មវិធីសិក្សា ដែលគេហៅម្យ៉ាងទៀតថា មធ្យោបាយបង្រៀននិងរៀន។

ភាសារួម (Lingua franca) ៖ ភាសាដែលគេនិយាយទូលំទូលាយ ដែលប្រើប្រាស់សម្រាប់ការប្រាស្រ័យទាក់ទងរវាងក្រុមមនុស្សដែលមកពីភាសាផ្សេងៗគ្នា។

ភាសាមូលដ្ឋាន (Local language) ៖ ភាសាដែលគេនិយាយនៅក្នុងសហគមន៍ផ្ទាល់។

ក្រុមភាគតិចខាងភាសា (Language minority) ៖ ក្រុមមនុស្សដែលមានភាសាដូចគ្នាតែមួយ ហើយជារឿយៗ មិនសូវមានអំណាច នៅក្នុងសង្គម ដោយសារតែចំនួន (ចំនួនតិចជាងគេ) សេដ្ឋកិច្ច (មិនសូវ មានទ្រព្យសម្បត្តិ) និង/ឬនយោបាយ។

អក្ខរកម្ម (Literacy) ៖ សមត្ថភាពអាន សរសេរ គណនា និងប្រើប្រាស់ភាសា ដើម្បីធ្វើអ្វីក៏បាន ដែលចាំបាច់ក្នុងជីវិត។

ភាសា និងវប្បធម៌ទូទៅ (Mainstream) ៖ ភាសា និងវប្បធម៌ របស់ក្រុមភាគច្រើន។

ភាសាដែលគនិយាយភាគច្រើន (Majority language) ៖ ភាសា ដែលនិយាយដោយមនុស្សភាគច្រើននៅក្នុងតំបន់មួយ / ប្រទេសមួយ។

ជនចំណាកស្រុក (Migrant) ៖ មនុស្ស ឬក្រុម ដែលផ្លាស់ទីពីតំបន់មួយ ទៅតំបន់មួយទៀត។

ភាសាដែលគេនិយាយភាគតិច (Minority language) ៖ ភាសាដែលនិយាយដោយក្រុមណាមួយក្នុងសង្គម និង/ឬក្រុមជនជាតិភាគតិច។

ការកៀរគរ (Mobilization) ៖ ដំណើរការនៃការចងក្រងសហគមន៍(និងអ្នកគាំទ្រ)ដើម្បីរួមគ្នារៀបចំផែនការ និងអនុវត្តកម្មវិធីអ្វីមួយ។

ភាសាកំណើត (MT) ៖ ភាសាទី ១ ភាសាកំណើត។

ពហុភាសា (Multilingual)

- កម្រិតបុគ្គល ៖ សមត្ថភាពនិយាយ យល់ (និងពេលខ្លះ អាន សរសេរ) ចាប់ពី ពីរភាសា ឡើងទៅ។
- កម្រិតសង្គម ៖ វត្តមាននៃក្រុមភាសាចាប់ពី ពីរឡើងទៅ។

ភាសាផ្លូវការ (Official language)៖ ភាសាដែលប្រើប្រាស់ដោយប្រទេសមួយសម្រាប់គោលបំណងរដ្ឋបាលសាធារណៈ និងស្ថាប័ន ហើយជារឿយៗ ជាភាសាដែលប្រើប្រាស់ក្នុងសាលារៀន។

ប្រព័ន្ធអក្ខរក្រម (Orthography) ៖ ប្រព័ន្ធស្តង់ដាសម្រាប់សរសេរភាសាមួយ ដូចជាអក្សរ និងរបៀបប្រកប និងវណ្ណយុត្ត ជាដើម។

និរន្តរភាព (Sustainability)៖ ការបង្កើតប្រព័ន្ធមួយ ដើម្បីឱ្យវាបន្តរយៈពេលយូរ។

ភាសាដែលមិនមានអក្សរ (Unwritten language) ៖ ភាសា ដែលគេនិយាយ ប៉ុន្តែមិនទាន់ប្រើ សម្រាប់អាន ឬសរសេរនៅឡើយ។

ប្រព័ន្ធសំណេរ (Writing system) ៖ ការបង្ហាញភាសានិយាយដោយប្រើសញ្ញា។

<u>និយមន័យផ្សេងទៀត ៖</u>

ការអប់រំពហុភាសា (Multilingual education) ៖ អាចមាននិយមន័យថា ជាការប្រើប្រាស់ភាសាចាប់ពីពីរឡើងទៅដោយមានផែនការ និងមានលក្ខណៈជាប្រព័ន្ធ នៅក្នុងកម្មវិធីមួយសម្រាប់បង្រៀនកុមារ។

ពហុភាសា (Multilingual)៖ កុមារនឹងប្រើភាសាពីរ ឬច្រើន រួមទាំងភាសាខ្មែរ នៅក្នុងការប្រាស្រ័យទាក់ទងរៀងរាល់ថ្ងៃ និងសម្រាប់ការរៀនសូត្ររបស់ពួកគេក្នុងសាលារៀន។

ពហុអក្ខរភាព (Multi-literate)៖ កុមារនឹងចេះអាន និងសរសេរភាសាពីរ ឬច្រើន ប្រកបដោយទំនុកចិត្ត។

ពហុវប្បធម៌ (Multicultural)៖ កុមារនឹងរស់នៅនិងធ្វើការងារយ៉ាងងាយស្រួលជាមួយមនុស្សមកពីខាងក្រៅសហគមន៍របស់ពួកគេ ហើយក្នុងពេលជាមួយគ្នានោះ កុមារនៅតែរក្សាសេចក្តីស្រឡាញ់ ការគោរពវប្បធម៌ និងសហគមន៍កំណើតរបស់ពួកគេ។

សហគមន៍ (Community)៖ សមាជិកសហគមន៍ មាតាបិតា និងចាស់ព្រឹទ្ធាចារ្យ ដែលចូលរួមយ៉ាងសកម្ម នៅក្នុងការពិនិត្យតាមដាន និងការគ្រប់គ្រងសាលារៀន។